១០០១ លំហាត់គណិតវិទ្យា

Vol 3

Problems and Solutions

ហៃ ប៉ាហ៊ិន	គរុនិស្សិតបរិញ្ញាបូក១គណិតវិទ្យា-រូបវិទ្យាជំនាន់ទី ១៧
ហៃ ចរិយា	សាស្ត្រាចារ្យគណិតវិទ្យាវិទ្យាល័យសុខអានសំរោង
យ៉ត ពន្លក	និស្សិតឆ្នាំទី៤បរិញ្ញាបត្រគណិតវិទ្យា



មិថុនា, ឆ្នាំ ២០១២

១០០១

លំហាត់គណិតវិទ្យា

ភាគ៣ (Vol 3)

រៀបរៀងដោយ

លោក ហែ ប៉ាហ៊ុន

(គ្រូបរិញ្ញាបត្រគណិតវិទ្យា និងរូបវិទ្យា)

(សមាជិកនិពន្ធទស្សនាវដ្ដីគណិតវិទ្យានៃកម្ពុជា និងការអប់រំ)

សហការរៀបរៀងដោយ

កញ្ញា ហែ ចរិយា

(គ្រូគណិតវិទ្យា និងនិស្សិតបរិញ្ញាបត្រគណិតវិទ្យាឆ្នាំទី៤)

លោក យ៉ត ពន្លក

(និស្សិតបរិញ្ញាបត្រគណិតវិទ្យាឆ្នាំទី៤)

កុំព្យូទ័រដោយ

លោក ហែ ប៉ាហ៊ុន

លោក ឈិត សារី

(និស្សិតបរិញ្ញាបត្រសង្គមវិទ្យាឆ្នាំទី៤)

ភ្នំពេញ , កម្ពុជា ខែ មិថុនា

ព.ស. ២៥៥៦ គ.ស. ២០១២

<u>សេចក្តីថ្លែងអំណរគុណ</u>

សៀវភៅមួយក្បាលនេះ សម្រេចបានជារូបរាងឡើងបានដោយសារតែមានការជ្រោមជ្រែងពីសំណាក់ ៖

លោក **គីម ពន្លក** នាយកវិទ្យាល័យប៊ុនរ៉ានី ហ៊ុនសែនស្លារម

លោក **ម៉ែន រាំង** សាស្ត្រាចារ្យគណិតវិទ្យា , វិទ្យាស្ថានជាតិអប់រំ

លោកស្រី **ទី ប៉ូលីណេត** សាស្ត្រាចារ្យគណិតវិទ្យា , វិទ្យាស្ថានជាតិអប់រំ

លោក **ថៃ ហេង** សាស្ត្រាចារ្យគណិតវិទ្យា , វិទ្យាស្ថានជាតិអប់រំ

លោក **ចាន់ រ៉ាដា** សាស្ត្រាចារ្យគណិតវិទ្យា , វិទ្យាស្ថានជាតិអប់រំ

លោក **លឹម បូណា** សាស្ត្រាចារ្យគណិតវិទ្យា , វិទ្យាស្ថានជាតិអប់រំ

លោក **ផាន់ សុតាព** សាស្ត្រាចារ្យគណិតវិទ្យា , វិទ្យាស្ថានជាតិអប់រំ

លោក **គឹម ចំរើនវុឌ្ឍី** សាស្ត្រាចារ្យគណិតវិទ្យា , វិទ្យាស្ថានជាតិអប់រំ

លោក **ឃឹម អាយុវឌ្ឍនៈវិជ្ជា** មន្ត្រីស្រាវជ្រាវគណិតវិទ្យានៃរាជបណ្ឌិតសភាកម្ពុជា

លោក **កៅ មុយសាន** មន្ត្រីស្រាវជ្រាវគណិតវិទ្យានៃរាជបណ្ឌិតសភាកម្ពុជា

លោក **ហេង ប៉ោហ៊ិន** សាស្ត្រាចារ្យគណិតវិទ្យា , សាកលវិទ្យាល័យភូមិន្ទភ្នំពេញ

លោក **ហ៊ិត ស៊ីអាត** អធិការគណិតវិទ្យារាជធានីភ្នំពេញ

លោក **អ៊ុន តាព** សាស្ត្រាចារ្យគណិតវិទ្យា , វិទ្យាល័យសម្តេចឪ

លោក **ប៉ោក ស្រេន** សាស្ត្រាចារ្យគណិតវិទ្យា , មជ្ឈមណ្ឌលគរុកោសល្យភូមភាគតាកែវ

លោក **លី សាម៉ាល់** សាស្ត្រាចារ្យគណិតវិទ្យា , មជ្ឈមណ្ឌលគរុកោសល្យភូមភាគតាកែវ

លោក **ម៉េង រិន** សាស្ត្រាចារ្យគណិតវិទ្យា , មជ្ឈមណ្ឌលគរុកោសល្យភូមភាគតាកែវ

លោក **ស៊ូ សែន** ប្រធានក្រុមបច្ចេកទេសគណិតវិទ្យា,វិទ្យាល័យប៊ុនរ៉ានី ហ៊ុនសែនស្លារម

លោក **ប៉ែន សំអុល** សាស្ត្រាចារ្យគណិតវិទ្យា,វិទ្យាល័យប៊ុនរ៉ានី ហ៊ុនសែនស្លារម

លោក **ហួរហៃ** តក្កី សាស្ត្រាចារ្យគណិតវិទ្យា,វិទ្យាល័យប៊ុនរ៉ានី ហ៊ុនសែនស្លារម

លោកស្រី **ឈិត ចាន់** ជាភរិយា និងកូនប្រុស **ហៃហ្ស មុនីសុធា**

មិត្តអ្នកអានទាំងអស់ដែលតែងតែគាំទ្រ យើងខ្ញុំ និងមិត្តរួមជំនាន់ទី ១៧ ទាំងអស់ ។

រាល់កំហុសឆ្គងផ្នែកបច្ចេកទេស និងអក្ខរាវិរុទ្ធក្នុងសៀវភៅនេះ មិនមែនជាកំហុសរបស់លោក លោកស្រីទាំងអស់ខាងលើនេះទេ , វាគឺជាកំហុសឆ្គងរបស់យើងខ្ញុំអ្នករៀបរៀង និងវាយកុំព្យូទ័រតែប៉ុណ្ណោះ ។

ពេលនេះខ្ញុំបាទសូមសម្តែងចេញនូវទឹកចិត្តដឹងគុណចំពោះ ៖

- លោកឪពុក **ហៃ ហួ** និងអ្នកម្តាយ **ហួត ឆៀខ** ដែលបានបង្កើត បិញ្ចឹម អប់រំ ប្រៀនប្រដៅកូន ទំនុកបំរុងកូន ឲ្យកូនមានថ្ងៃនេះ ។
- លោកគ្រូ/អ្នកគ្រូដែលធ្លាប់បានបង្ហាត់បង្រៀនដល់រូបខ្ញុំបាទតាំងពីតូចរហូតដល់សព្វថ្ងៃ ។ លោកគ្រូ មួយចំនួនក៏បានចែកឋានទៅហើយ ។ ការខិតខំរបស់លោកគ្រូ/អ្នកគ្រូដែលបានបង្ហាត់បង្រៀនខ្ញុំ ក៏ដូចជាកូនខ្មែរដទៃទៀត គឺជាគុណូបការៈយ៉ាងធំធេង ។
- បងប្អូនប្រុស/ស្រី ទាំងអស់របស់ខ្ញុំបាទ ដែលធ្លាប់រស់នៅក្រោមដំបូលតែមួយ ។

សូមឲ្យលោកអ្នកមានគុណទាំងអស់ បានជួបតែសេចក្តីសុខ សេចក្តីចម្រើនគ្រប់ៗគ្នា ។

ថ្ងៃទី ១៩ ខែ ឧសភា ឆ្នាំ ២០១២ , ម៉ោងប្រហែលជា ១៧ ល្ងាច ។ សម្លេងសោយសោកដ៏គួរឲ្យអាណិតអាសូរ ។ បងជីដូនមួយរបស់ភរិយាខ្ញុំម្នាក់ បានលាចាកលោកសន្និវាសនេះ ដែលបន្សល់ទុកនូវសេចក្តីទុក្ខដ៏ក្រៀមក្រំ មិនមានអ្នកណាដែលទ្រាំទប់ទឹកភ្នែកបាន ។ គាត់មានអាយុ ៣២ ឆ្នាំ , គាត់ជាមនុស្សស្លូតបូត មានប្រជាប្រិយ រួសរាយរាក់ទាក់ មនុស្សផងទាំងពួងដែលស្គាល់គាត់ គឺស្រឡាញ់រាប់អានគាត់គ្រប់ៗគ្នា , គាត់ធ្វើតែអំពើល្អ ។ គាត់ស្លាប់ដោយសារជំងឺ ក្រោយពីត្រឡប់មកពីពេទ្យប្រទេសវៀតណាមវិញបាន កន្លះខែ ។ ពេទ្យវៀតណាមវះពោះគាត់ ហើយពិនិត្យមើលជំងឺនៅលើពោះវៀនគាត់ គឺមានពេញដោយ កូនកណ្តុរ ហើយពេទ្យក៏ដេរវិញ ។ គេអត់ហ៊ានព្យាបាលទេ ហើយនិយាយប្រាប់ថាគាត់អាចរស់បានត្រឹមតែ ៦ ខែទៀតប៉ុណ្ណោះ ។ ក្រុមគ្រួសារក៏លាក់រឿងនេះមិនឲ្យសាមីខ្លួន និងប្រពន្ធរបស់គាត់ដឹងទេ , ហើយនាំគាត់មកខ្មែរវិញ ខិតខំមើលគ្រូខ្មែរវិញ ទាំងមិនសូវមានសង្ឃឹម ។ ១៥ ថ្ងៃក្រោយពីមកពីវៀតណាមវិញ គាត់ក៏បានលាចាកលោក ។ គាត់ទើបតែជួបជុំគ្នាជាមួយខ្ញុំនៅថ្ងៃសែន មុនចូលឆ្នាំខ្មែរ គឺមិនមានអីផង គ្រាន់តែឈឺបន្តិចបន្តួចតែនៅដើរ រត់ បើកឡានធម្មតា។ មុនពេលគាត់ស្លាប់ គាត់បានផ្តែផ្តាំប្អូនៗឲ្យជួយថែរក្សាឪពុកម្តាយ ហើយផ្តាំម្តាយឪពុកក្មេក ឲ្យជួយមើលថែរទាំប្រពន្ធ កូនរបស់គាត់ផង ។កូនស្រីច្បងរបស់គាត់អាយុប្រហែលជិត ៤ឆ្នាំ ។ កូនទី២ នៅក្នុងផ្ទៃម្តាយទើបបាន ៦ខែ ។ គាត់និយាយរហូត ខ្សោយទៅៗ ទាល់តែកម្លាំងថយដល់ចំណុចសូន្យ ក៏ផុតដង្ហើមទៅ ។ មនុស្សម្នា អ្នកស្រុកអ្នកភូមិ បងប្អូនមកជួបជុំគ្នាពេញក្រោមផ្ទះ ។ ម្នាក់ៗយំរហូតទាល់តែយំលេងចេញ ។ គាត់ស្លាប់ទៅគេក៏រៀបចំបុណ្យសពទៅតាមប្រពៃណី ។ កូនរបស់គាត់ចេះតែសួរម្តាយថា “ម៉េចក៏ប៉ាដេកយូរម្លេះ” ។ ...

សេចក្តីស្លាប់គឺវាអញ្ចឹង ។ សូមមិត្តអ្នកអានមេត្តាគិតពីអនាគតរបស់យើង និងកូនចៅយើងផង ។ កុំគិតតែអ្វីដែលនៅជិតៗ ។ សម័យនេះទៅហើយ គេមើលឃើញដល់ណាណី ហើយ សូមយើងកុំធ្វើជាកង្កែបក្នុងអណ្តូងទៀត ។

អារម្ភកថា

សៀវភៅ “១០០១ លំហាត់គណិតវិទ្យា Vol 3” ដែលមិត្តអ្នកអានកំពុងកាន់នៅនឹងដៃនេះគឺជាសមិទ្ធកម្ម មួយដែលឆ្លើយតបទៅនឹងតម្រូវការរបស់មិត្តអ្នកសិក្សាស្របតាមការយកចិត្តទុកដាក់របស់ពិភពលោកលើវិស័យអប់រំ ។ គណិតវិទ្យាគឺជាមុខវិជ្ជាមួយយ៉ាងសំខាន់ ហើយមិនសូវជាមានអ្នកដែលរៀនបានពូកែលើមុខវិជ្ជានេះណាស់ ចង់ពូកែគណិតវិទ្យានេះ គឺត្រូវចាប់ផ្តើមតាំងពីថ្នាកបឋមសិក្សាទី១ ទី២... មកម្ល៉េះ ។ កាលណាប្អូនៗពូកែគណិតវិទ្យា នោះប្អូនៗនឹងមានឱកាសច្រើនក្នុងការទទួលបានជោគជ័យលើមុខវិជ្ជាផ្សេងៗទៀត ក៏ដូចជាការងារដែរ ។

សៀវភៅនេះក៏បាននាំមកនូវរឿងទុក្ខសោកមួយនៅខាងដើម តែនេះមិនមែនជាសញ្ញាមិនល្អទេ តែជារឿងមួយឲ្យមិត្តអ្នកអានចេះស្រឡាញ់អាយុជីវិតរបស់ខ្លួន ចេះធ្វើឲ្យជីវិតរបស់ខ្លួនមានន័យ មានកិត្តិយស ។ បើមិត្តអ្នកអានយល់ថាត្រង់ណាមិនល្អ សូមមិត្តអ្នកអានហែកសន្លឹកនោះចោលទៅ ដើម្បីកុំឲ្យជាភាពហ្មងសៅ ហើយទូរសព្ទមកខ្ញុំដើម្បីឲ្យខ្ញុំមានការកែសម្រួលនៅស្នាដៃលើកក្រោយៗទៀត ។

ឆ្នាំ ២០១២ កន្លងទៅនេះ សិស្សពូកែគណិតវិទ្យាទូទាំងប្រទេសថ្នាក់ទី១២ ត្រូវបានសិស្សតាមខេត្តនានា ដណ្តើមយកទាំងអស់ ដែលរាល់ឆ្នាំមានច្រើនតែភ្នំពេញ តែឆ្នាំនេះវាផ្សេង ។ នេះមិនមែនមានន័យថា សិស្សនៅភ្នំពេញខ្សោយនោះទេ តែគឺមានន័យថាសិស្សតាមបណ្តាខេត្តនានាក៏មិនអាចមើលស្រាលបានដែរ ។ នេះហើយគឺជាការរីកចម្រើនខាងវិស័យអប់រំស្រុកយើងលើសិស្សពូកែ ។

សូមឲ្យមិត្តអ្នកសិក្សាខិតខំបន្ថែមទៀត ដើម្បីជាទំពាំងស្នងឫស្សី ដ៏រឹងមាំ ។ យើងខ្ញុំសូមរង់ចាំទទួលនូវការរិះគន់គ្រប់មជ្ឈដ្ឋានអ្នកសិក្សា ។

ភ្នំពេញ , ថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ ២០១២

អ្នករៀបរៀង

ហៃ ប៉ាហ៊ិន

ទូរសព្ទ ០១២ ៣៤៧ ៦២៤

អ៊ីម៉ែល **pahen_hay@yahoo.com**

ផ្នែកលំហាត់

201. ដោយមិនប្រើម៉ាស៊ីនគិតលេខ , ចូរបង្ហាញថា ៖ $\sqrt[3]{43}<\sqrt[3]{9}+\sqrt[3]{3}<\sqrt[3]{44}$ ។

202. គេឲ្យ ΔABC មានក្រឡាផ្ទៃ $S=1$ ។ បង្ហាញថា ៖ $a^4+b^4+c^4\geq 16$ ។

203. រកតម្លៃអតិបរមារបស់កន្សោម ៖ $A=\sin\alpha_1\cdot\sin\alpha_2\cdot\ldots\cdot\sin\alpha_{2013}$, បើគេដឹងថា ៖
$\tan\alpha_1\cdot\tan\alpha_2\cdot\ldots\cdot\tan\alpha_{2013}=1$ ។

204. សុខជ្រើសរើសបួនចំនួនផ្សេងគ្នាចេញអំពីសំណុំ $\{1,2,3,4,5,6,7\}$ ដែលមានផលបូកស្មើនឹង 11 ។ បើ L គឺជាចំនួនដែលធំបំផុតក្នុងចំណោមចំនួនទាំងបួននោះ ។ ចូរកំណត់តម្លៃនៃ L ។

205. ដោះស្រាយសមីការ ៖

ក. $\left(2\cos 3x+6\cos x+1\right)^3=162\cos x-27$

ខ. $3^{2013x+3\cos x}-3^{2013x+4\cos^3 x}-3\cos 3x=0$

គ. $\left(\sin x\right)\sqrt[2012]{\sin^2 x+2012}-\left(\cos x+1\right)\sqrt[2012]{\cos^2 x+2\cos x+2013}=\cos x-\sin x+1$

ឃ. $\tan x=\cos^2\left(2x+\dfrac{5\pi}{12}\right)+\sin^2\left(2x+\dfrac{5\pi}{12}\right)+\sin x\sin\left(3x+\dfrac{5\pi}{6}\right)$ ។

206. x,y និង z គឺជាចំនួនពិតធំជាង 1 ហើយ w គឺជាចំនួនពិតវិជ្ជមានមួយ ។
បើ $\log_x w=24,\log_y w=40$ និង $\log_{xyz} w=12$ ។ រកតម្លៃនៃ $\log_z w$ ។

207. ឧបមាថាពន្លាតកន្សោម ៖

$\left(1-3x+4x^2\right)^{502}\left(1+3x-4x^2\right)^{504}=a_nx^n+a_{n-1}x^{n-1}+\cdots+a_1x+a_0$ ។

ក. តើ n ស្មើនឹងប៉ុន្មាន ?

ខ. គណនាផលបូក $S=a_{2012}+a_{2011}+\cdots+a_1+a_0$ ។

208. ដោះស្រាយប្រព័ន្ធសមីការ ៖

$$\begin{cases}\lfloor x\rfloor+3\{y\}=3.9\\ \{x\}+3\lfloor y\rfloor=3.4\end{cases}$$

209. យើងមាន ABC ជាត្រីកោណសមបាតដែល $AB=AC$ ។ សន្មតថាកន្លះបន្ទាត់ពុះនៃមុំ $\angle B$ កាត់ជ្រុង AC ត្រង់ D និង $BC=BD+AD$ ។ កំណត់តម្លៃ $\angle A$ ។

210. ស្រមោចមួយស្ថិតនៅត្រង់កំពូល V នៃគូបមួយដែលមានរង្វាស់ជ្រុងនីមួយៗ $1m$ ។ ស្រមោចនោះត្រូវផ្លាស់ទីតាមជ្រុងនីមួយៗរបស់គូប និងត្រឡប់មកកំពូល V វិញ ដោយមិនឆ្លងកាត់តាមចំណុចណាមួយពីរដងឡើយ ។
រកប្រវែងវែងបំផុតនៃគន្លង ។



211. ដោះស្រាយសមីការខាងក្រោម ៖

ក. $\sqrt{x-2\sqrt{x-1}}+\sqrt{x+3-4\sqrt{x-1}}=1$

ខ. $\sqrt{1-x}=\sqrt{6-x}-\sqrt{-5-2x}$ ។

212. គណនាមាឌនៃសូលីតខាងក្រោម គិតជា cm^3 ។ សូលីតនេះគឺជាប្រអប់ដែលមានប្រហោងខាងក្នុងគឺជាការ៉េ ។ រង្វាស់នៅក្នុងរូបគិតជា cm ។



213. បង្ហាញថា ចំពោះគ្រប់ចំនួនពិតវិជ្ជមាន a,b,c គេបាន ៖

$$\frac{1}{a^3+b^3+abc}+\frac{1}{b^3+c^3+abc}+\frac{1}{c^3+a^3+abc}\le\frac{1}{abc} \text{ ។}$$

214. រង្វង់ $C:x^2+y^2+kx+(1+k)y-(k+1)=0$ កាត់តាមពីរចំណុចជានិច្ចគ្រប់តម្លៃ k ។

១. រកកូអរដោនេនៃពីរចំណុចនោះ ។

២. រកតម្លៃអប្បបរមានៃកាំរបស់រង្វង់នោះ ។

215. តាង $x>0$, $y>0$, $xy=8$ និង $P=2(\log_2 x)^2+(\log_2 y)^2$ ។

១. តាង $X=\log_2 x$ ។ សរសេរកន្សោម P ទៅជាអនុគមន៍នៃ X ។

២. រកតម្លៃអប្បបរមានៃ P ។

216. គេមានបួនចំណុច A,B,C និង D ឋិតនៅលើកន្លះរង្វង់មួយដូចរូប ។ កាំនៃកន្លះរង្វង់នេះគឺ 1 ឯកតា ហើយផ្ចិតរបស់វាគឺ O ។ CD គឺជាអង្កត់ផ្ចិត និងសមាមាត្រនៃក្រឡាផ្ទៃត្រីកោណគឺ ៖ $S_{\Delta OAB}:S_{\Delta OBC}:S_{\Delta OCD}=1:2:2$ ។

១. តាង $\alpha=\angle AOB$ និង $\beta=\angle BOC$ ។ រក $\sin\alpha:\sin\beta$ ។

២. រកក្រឡាផ្ទៃនៃចតុកោណ $ABCD$ ។



217. មានចំណុច A មួយនៅលើខ្សែកោង $C:x^2+y^2-2x-4=0$ ។ បើបន្ទាត់ប៉ះនឹង C ត្រង់ A កាត់តាមចំណុច $P(4,3)$ ។ ចូរគណនាប្រវែង AP ។

218. គេមាន ABC គឺជាត្រីកោណមួយដែលមាន $AB=5, BC=4$ និង $\angle B=60^o$ ។

១. រកប្រវែងនៃអង្កត់ធ្នូ AC ។

២. គណនាប្រវែងកាំរង្វង់ចារឹកក្រៅត្រីកោណ ABC ។

៣. D គឺជាចំណុចមួយនៅលើធ្នូតូច AC ។ រកតម្លៃអតិបរមានៃផ្ទៃក្រឡារបស់ចតុកោណ $ABCD$ ។



219. ដោះស្រាយសមីការ $3x^3-10x^2+10x-4=0$ ។

220. គេមាន α និង β ជាឫសរបស់សមីការ $2x^2-5x+1=0$ ហើយ $\frac{1}{\alpha}$ និង $\frac{1}{\beta}$ ជាឫសរបស់សមីការ $x^2+ax+b=0$ ។ រកតម្លៃនៃចំនួនថេរ a និង b ។

221. តាង $\alpha=2, \beta=\sqrt{3}+i$ និង $\gamma=1+i$, $\left(i^2=-1\right)$ ។ រកតម្លៃដាច់ខាត r (ម៉ូឌុល) និងអាគុយម៉ង់ θ នៃ $\frac{\alpha+\beta}{\gamma}$, $(-\pi<\theta\le\pi)$ ។

222. សន្មតថា $\lim_{x\to\infty}\left(1+\frac{1}{kx}\right)^x=\sqrt{e}$ ។ រកតម្លៃនៃចំនួនថេរ k ។

223. សន្មតថា α និង 3α គឺជាចម្លើយនៃសមីការត្រីជាដឺក្រេទី២ $3x^2+8x+k=0$ ដែល k គឺជាចំនួនពិត ថេរ ។ រកតម្លៃនៃ k ។

224. គេមាន a គឺជាផ្នែកគត់ នៃ $\frac{1}{2-\sqrt{3}}$ និង b គឺជាផ្នែកទសភាគ ($0<b<1$) ។

ចូរគណនាតម្លៃនៃ $a-b+\frac{2}{b}$ ។

225. សន្មតថា $\log_{10}A=a$ និង $\log_{10}B=b$ ចំពោះគ្រប់ចំនួនពិតវិជ្ជមាន A,B ខុសពី 1 ។ ឧបមាថា $a+b=0$ ។ រកតម្លៃនៃ $A^{\frac{1}{b}}B^{\frac{1}{a}}$ ។

226. បង្ហាញថា ចំពោះចំនួនគត់វិជ្ជមាន n នីមួយៗ , នោះមានចំនួនគត់វិជ្ជមាន m មួយដែលផ្ទៀងផ្ទាត់ $\left(1+\sqrt{2}\right)^n=\sqrt{m}+\sqrt{m+1}$ ។

227. តាង $x,y,z\ge 0$ ហើយផ្ទៀងផ្ទាត់ $x+y+z=3$ ។ បង្ហាញថា ៖

$$\frac{x^3}{y^3+8}+\frac{y^3}{z^3+8}+\frac{z^3}{x^3+8}\ge\frac{1}{9}+\frac{2}{27}\cdot(xy+yz+zx) ~ ។$$

តើសញ្ញាសមភាពកើតមាននៅពេលណា ?

228. យើងមាន $ABCD$ គឺជាចតុកោណប៉ោងមួយ តាង $\alpha=\angle DAB,\beta=\angle ADB,\gamma=\angle ACB$ $\delta=\angle DBC$ និង $\varepsilon=\angle DBA$ ។ សន្មតថា $\alpha<\frac{\pi}{2},\beta+\gamma=\frac{\pi}{2}$ និង $\delta+2\varepsilon=\pi$ ។

បង្ហាញថា $(DB+BC)^2=AD^2+AC^2$ ។

229. រកពហុធាដឺក្រេទី៥ $p(x)$ ដែលផ្ទៀងផ្ទាត់ $p(x)+1$ ចែកដាច់នឹង $(x-1)^3$ និង $p(x)-1$ ចែកដាច់នឹង $(x+1)^3$ ។

230. ពហុធា $P(x)$ មានដឺក្រេទី n ដែលផ្ទៀងផ្ទាត់លក្ខខណ្ឌ $P(k)=2^k$ បំពោះ $k=0,1,2,\ldots,n$ ។ រកតម្លៃនៃ $P(n+1)$ ។

231. សន្មតថា $\frac{3}{2}\le x\le 5$ ។ បង្ហាញថា $2\sqrt{x+1}+\sqrt{2x-3}+\sqrt{15-3x}<2\sqrt{19}$ ។

232. តាង θ ជាមុំស្រួចមួយ ដែលផ្ទៀងផ្ទាត់សមីការអញ្ញាត x , $x^2+4x\cos\theta+\cot\theta=0$ មានឫសឌុប ។ ចូររកតម្លៃនៃ θ ។

233. រកគ្រប់ចំនួនគត់ x ដែល $(4-x)^{4-x}+(5-x)^{5-x}+10=4^x+5^x$ ។

234. គេមាន O ជាចំណុចមួយនៅខាងក្នុងត្រីកោណ ABC ដែល $\overrightarrow{OA}+2\overrightarrow{OB}+3\overrightarrow{OC}=\vec{0}$ ។ ចូររកផលធៀបនៃក្រឡាផ្ទៃរបស់ត្រីកោណ ABC ជាមួយក្រឡាផ្ទៃរបស់ត្រីកោណ AOC ។

235. ស្ត្រីម្នាក់ បានកើត និងរស់នៅក្នុងសតវត្សទី ២០ ។ ដោយដឹងថាការ៉េនៃអាយុរបស់គាត់ស្មើនឹងឆ្នាំដែលគាត់រស់នៅ ។ ចូររកអាយុរបស់គាត់នៅឆ្នាំ ១៩៨៨ ។

236. ដោះស្រាយសមីការ ៖ $2\left(x^2-3x+2\right)=3\sqrt{x^3+8}$ ។

237. ដោះស្រាយសមីការ ៖ $\sin^2 x+\sin^2 2x+\sin^2 3x=\frac{3}{2}$ ។

238. គេឲ្យ A,B,C ជាមុំទាំងបីរបស់ត្រីកោណមួយ ។

១. បង្ហាញថា $\dfrac{\cot\frac{A}{2}\cdot\cot\frac{B}{2}\cdot\cot\frac{C}{2}}{\cot\frac{A}{2}+\cot\frac{B}{2}+\cot\frac{C}{2}}=1$ ។

២. សន្មតថា $\cos C\cdot(\sin A+\sin B)=\sin C\cdot\cos(A-B)$ ។ ចូរកំណត់ $\cos A+\cos B$ ។

239. រកគ្រប់ពហុធា $f(x)$ ដែលមានមេគុណជាចំនួនពិត ហើយផ្ទៀងផ្ទាត់លក្ខខណ្ឌ ៖

$$f(x)\cdot f(x+1)=f\left(x^2+x+1\right)$$ ។

240. អនុគមន៍ $f(x)$ ផ្ទៀងផ្ទាត់លក្ខខណ្ឌខាងក្រោម ៖

(i) បំពោះគ្រប់ចំនួនសនិទាន x , $f(x)$ គឺជាចំនួនពិត

(ii) $f(2013)\neq f(2012)$

(iii) $f(x+y)=f(x)f(y)-f(xy)+1$ បំពោះគ្រប់ចំនួនសនិទាន x និង y

បង្ហាញថា $f\left(-\frac{2012}{2013}\right)=\frac{1}{2013}$ ។

241. រកគ្រប់អនុគមន៍ f ដែល ៖

(i) យកតម្លៃជាចំនួនពិត

(ii) កំណត់បានគ្រប់ចំនួន $x\neq\frac{2}{3}$, និង

(iii) ផ្ទៀងផ្ទាត់លក្ខខណ្ឌ

$503x-f(x)=\frac{1}{2}f\left(\frac{2x}{3x-2}\right)$ ចំពោះគ្រប់តម្លៃនៃ x លើកលែង $\frac{2}{3}$ ។

242. ចំពោះអនុគមន៍ f ដែលកំណត់លើគ្រប់ចំនួនពិត និងផ្ទៀងផ្ទាត់លក្ខខណ្ឌ ៖

$f(xy)=x\cdot f(y)+f(x)\cdot y$ និង $f(x+y)=f\left(x^{2013}\right)+f\left(y^{2013}\right)$ ។

ចូរកំណត់តម្លៃនៃ $f\left(\sqrt{2556}\right)$ ។

243. គេឲ្យចតុកោណប៉ោង $ABCD$ ។ សន្មត M,N គឺជាចំណុចកណ្តាលនៃ AB,CD ។

បង្ហាញថា ៖

ក. $2\overrightarrow{MN}=\overrightarrow{AC}+\overrightarrow{BD}=\overrightarrow{AD}+\overrightarrow{BC}$ ។

ខ. $MN\leq\max(AD,BC)$ ។

244. ដោះស្រាយប្រព័ន្ធវិសមីការ ៖ $\begin{cases}4^{x+y-1}+3\cdot4^{2y-1}\leq2\\ x+3y\geq2-\log_4 3\end{cases}$ ។

245. ដោះស្រាយប្រព័ន្ធវិសមីការ ៖ $\begin{cases}\log_{\frac{1}{5}}\sqrt{5-x}<\log_{\frac{1}{5}}(3-x)\\ \left(x+\frac{1}{3}\right)\in\mathbb{N}\end{cases}$ ។

246. ស្រាយបញ្ជាក់ថា ៖

ក. $2222^{5555}+5555^{2222}$ ចែកដាច់នឹង 7 ។

ខ. $2010^{2011}+2012^{2013}+2014^{2015}+3$ ចែកដាច់នឹង 7 ។

247. គេឲ្យចំនួនពិត m និង n ដែលផ្ទៀងផ្ទាត់ $11m+10n=9$ ។

ចូរគណនាតម្លៃអតិបរមានៃអនុគមន៍ពីរអថេរ $f(m,n)=(m+9)(n+6)(10m+9n)$ ។

248. បើ a,b,c,d ជាចំនួនពិតដែលផ្ទៀងផ្ទាត់ $a^2+b^2+c^2+d^2=2013^2$ ។

បង្ហាញថា $a^3+b^3+c^3+d^3\leq2013^3$ ។

249. រកគ្រប់អនុគមន៍ $f:\mathbb{R}\to\mathbb{R}$ ដែលផ្ទៀងផ្ទាត់លក្ខខណ្ឌ $f\left(xf(y)+x\right)=xy+f(x)$

ចំពោះគ្រប់ចំនួនពិត x និង y ។

250. នៅក្នុងរូប, $AQPB$ និង $ASRC$ គឺជាការ៉េ ហើយ AQS គឺជាត្រីកោណសម័ង្ស ។

បើ $QS=4$ និង $BC=x$ ។ ចូររកតម្លៃនៃ x ។



251. $ABCD-EFGH$ គឺជាគូបមួយដែលមាន $ABCD$ ជាមុខលើ , តាមកំពូល H,G,F និង E គូសបន្ទាត់ដោយផ្ទាល់ភ្ជាប់ទៅកំពូល A,B,C និង D រៀងគ្នា ។ ចំនួនពិតមួយត្រូវបានដាក់នៅតាមកំពូលនីមួយៗ ។ ត្រង់កំពូលនីមួយៗ , មធ្យមនៃចំនួនក្នុងកំពូលជាប់គ្នាបី ។ មធ្យមដែលបិតនៅត្រង់ A,B,C,D,E,F,G,H គឺ $1,2,3,4,5,6,7,8$ រៀងគ្នា ។ រកចំនួនដែលបិតនៅត្រង់កំពូល F ។

252. គេឲ្យស្វ៊ីត ហ្វីបូណាស៊ី (u_n) កំណត់ដោយ ៖ $u_0=0, u_1=1$ និង $u_{n+1}=u_n+u_{n-1}$ គ្រប់ $n\ge 1$ ។

ក. រក u_n ជាអនុគមន៍នៃ n ។

ខ. បង្ហាញថា $u_1+u_2+\cdots+u_n=u_{n+2}-1$ គ្រប់ $n\in\mathbb{N}$ ។

253. ក. បង្ហាញថា $A=11^{10}-1$ ចែកដាច់នឹង 600 ។

ខ. រកគ្រប់ចំនួនគត់ធម្មជាតិ n ដែលផ្ទៀងផ្ទាត់ $B=2^n+1$ ចែកដាច់នឹង 3 ។

254. ដោះស្រាយសមីការ $8x^3+24x^2+6x-1=0$ ។

255. ក. គេឲ្យសមីការ $x^4+bx^3+cx^2+bx+1=0$ មានឫស ។ បង្ហាញថា $b^2+(c-2)^2>3$ ។

ខ. ដោះស្រាយសមីការ $x^3+3x-3=0$ ។

256. សន្មត m,n,p ជាឫសចំនួនពិតទាំងបីរបស់សមីការ ៖ $ax^3+bx^2+cx-a=0$, $a\neq 0$ ។

បង្ហាញថា $\dfrac{\sqrt{2}}{m}+\dfrac{\sqrt{3}}{n}-\dfrac{\sqrt{2+\sqrt{3}}}{p}\le m^2+n^2+p^2$, តើសមភាពកើតមាននៅពេលណា ?

257. គេឲ្យកន្សោម ៖

$$S=\cos\frac{\pi}{11}+\cos\frac{3\pi}{11}+\cos\frac{5\pi}{11}+\cos\frac{7\pi}{11}+\cos\frac{9\pi}{11}$$

តើ S ជាចំនួនសនិទាន ឬទេ ?

258. គេមាន ABC ជាត្រីកោណដែលមានមុំទាំងបីជាមុំស្រួច , បង្ហាញថា ៖

១. $\tan A+\tan B+\tan C\ge 3\sqrt{3}$

២. $\tan A\cdot\tan B\cdot\tan C\ge 3\sqrt{3}$

៣. $\tan^n A+\tan^n B+\tan^n C\ge 3\cdot\sqrt[3]{\left(3\sqrt{3}\right)^n}$ ។

259. បង្ហាញថាបើសមីការ $(x+a)^2+(y+b)^2+(x+y)^2=c^2$ មានឫស

នោះ $(a+b)^2\le 3c^2$ ។

260. រក $\displaystyle\lim_{n\to+\infty}\int_0^n\frac{e^{-x}}{1+e^{-\frac{x}{n}}}dx$ ។

261. រក $f:\mathbb{R}\to\mathbb{R}$ ដែលផ្ទៀងផ្ទាត់លក្ខខណ្ឌ ៖

(i) $f(x+y)\le f(x)+f(y)$, $\forall x,y\in\mathbb{R}$

(ii) $\displaystyle\lim_{x\to 0}\frac{f(x)}{x}=1$

262. សន្មតថាសមីការ $x^3-45x^2+6x-a=0$ មានឫសបី x_1,x_2,x_3 ។

បង្ហាញថាផលបូក $\Sigma=x_1^2+x_2^2+x_3^2$ មិនជាអនុគមន៍នៃ a ។

263. ដោះស្រាយប្រព័ន្ធសមីការ ៖

$$\begin{cases}(x+3y+4z+t)^2=27\left(x^2+y^2+z^2+t^2\right)\\ x^3+y^3+z^3+t^3=93\end{cases}$$

264. ដោះស្រាយ និងពិភាក្សា សមីការខាងក្រោម ទៅតាមតម្លៃប៉ារ៉ាម៉ែត a ៖

$\left|2|x|-a\right|=x-a$ ។

265. បង្ហាញថាត្រីកោណ ABC ដែលមានមុំផ្ទៀងផ្ទាត់ទំនាក់ទំនង ៖

$$\sin\frac{A}{2}\cos^3\frac{B}{2}=\sin\frac{B}{2}\cos^3\frac{A}{2}$$

នោះត្រីកោណ ABC ជាត្រីកោណសមបាត ។

266. គេមាន $\cos\alpha\cos\beta+\cos\beta\cos\gamma+\cos\gamma\cos\alpha=1$ ។

រកតម្លៃអប្បបរមារបស់កន្សោម $M=\cos^4\alpha+\cos^4\beta+\cos^4\gamma$ ។

267. បង្ហាញថាត្រីកោណ ABC មួយមានមុំទាំងបីផ្ទៀងផ្ទាត់លក្ខខណ្ឌ ៖

$$\sin 2A+\sin 2B+\sin 2C=\sin A+\sin B+\sin C$$

នោះ ABC ជាត្រីកោណសម័ង្ស ។

268. គេមានត្រីកោណ ABC មួយ មានផ្ទៃក្រឡា S និងកាំរង្វង់ចារឹកក្រៅ R ។

បើ $3S=2R^2\left(\sin^3 A+\sin^3 B+\sin^3 C\right)$

បង្ហាញថាត្រីកោណ ABC ជាត្រីកោណសម័ង្ស ។

269. ដោះស្រាយប្រព័ន្ធសមីការ ៖

$$\begin{cases}\sqrt{x^2+x+y+1}+x+\sqrt{y^2+x+y+1}+y=18\\ \sqrt{x^2+x+y+1}-x+\sqrt{y^2+x+y+1}-y=2\end{cases}$$

សមមូល ៖

$$\begin{cases}x-4=0\\ 4-y=0\end{cases}\Rightarrow x=y=4$$

ដូចនេះប្រព័ន្ធសមីការមានចម្លើយ $x=y=4$ ត្រូវបានដោះស្រាយ ។

270. គេឲ្យ a,b,c ជាបីចំនួនវិជ្ជមានដែលផ្ទៀងផ្ទាត់ $a+b+c=4$ ។

បង្ហាញថា $(a+b)(b+c)(c+a)\ge a^3b^3c^3$ ។

271. ដោះស្រាយប្រព័ន្ធសមីការ (អញ្ញាត្តិ x,y,z) ៖

$$\frac{xy}{ay+bx}=\frac{yz}{bz+cy}=\frac{zx}{cx+az}=\frac{x^2+y^2+z^2}{a^2+b^2+c^2}\ ។$$

272. គេឲ្យ a និង b ជាពីរចំនួនវិជ្ជមានផ្សេងពីគ្នា ។

បង្ហាញថា $\sqrt{ab}<\dfrac{a-b}{\ln a-\ln b}<\dfrac{a+b}{2}$ ។

273. គេឲ្យ a,b,c ជាបីចំនួនពិតមិនសូន្យ ផ្ទៀងផ្ទាត់ ៖

$$\frac{ay-bx}{c}=\frac{cx-az}{b}=\frac{bz-cy}{a}$$

បង្ហាញថា $(ax+by+cz)^2=\left(x^2+y^2+z^2\right)\left(a^2+b^2+c^2\right)$ ។

274. គេឲ្យសមីការពហុធាដឺក្រេទី២ ៖ $x^2-6x+m=0$ ។
កំណត់តម្លៃរបស់ប៉ារ៉ាម៉ែត m ដើម្បីឲ្យសមីការខាងលើ មានឫសពីរ x_1,x_2 ដែលផ្ទៀងផ្ទាត់រិឡាស្យុង(ទំនាក់ទំនង) $x_1^3+x_2^3=72$ ។

275. គេឲ្យសមីការពហុធាដឺក្រេទី២ ៖ $ax^2+bx+c=0$ និង $px^2+qx+r=0$ មានឫសរួមមួយ ។ បង្ហាញថាយើងមានសមភាព $(pc-ar)^2=(pb-aq)(cq-rb)$ ។

276. ដោះស្រាយប្រព័ន្ធវិសមីការ ៖

$$\begin{cases} x_1+x_2-x_3-x_4<0 \\ (x_1+x_2)(x_3+x_4)-x_1x_2-x_3x_4<0 \\ (x_1+x_2)x_3x_4-(x_3+x_4)x_1x_2<0 \\ x_1>0, x_2>0, x_3>0, x_4>0 \end{cases} \text{ ។}$$

277. គេឲ្យ n ចំនួនគត់ $a_1,a_2,a_3,\dots,a_n$ មានផលបូក $a_1+a_2+\cdots+a_n$ ចែកដាច់នឹង 6 ។
បង្ហាញថាផលបូក $a_1^3+a_2^3+\cdots+a_n^3$ ចែកដាច់នឹង 6 ។

278. គេឲ្យ $x=\dfrac{1}{2-\sqrt{3}}$ ។ រកតម្លៃនៃ $x^6-2\sqrt{3}x^5-x^4+x^3-4x^2+2x-\sqrt{3}$ ។

279. រកគ្រប់អនុគមន៍នៃចំនួនពិត $f:\mathbb{R}\to\mathbb{R}$ ដែលផ្ទៀងផ្ទាត់
$f(x^3-y)+2y(3f^2(x)+y^2)=f(y+f(x))$ គ្រប់ $x,y\in\mathbb{R}$ ។

280. បង្ហាញថាគ្រប់ចំនួនពិត a,b,c បើ $(a+c)(a+b+c)<0$ នោះ
$(b-c)^2>4a(a+b+c)$ ។

281. គេឲ្យស្វ៊ីតនៃចំនួនពិត $x_0,x_1,x_2,\dots,x_n,\dots$ កំណត់ដោយ ៖

$$x_0=2014 \text{ និង } x_n=-\frac{2014}{n}\sum_{k=0}^{n-1}x_k \quad ,(n\ge 1) \text{ ។}$$

កំណត់តម្លៃនៃផលបូក $A=\sum\limits_{n=0}^{2014}2^n\cdot x_n$ ។

282. គេមានត្រីកោណមួយមានរង្វាស់ជ្រុង a,b,c ហើយ p និង S គឺជាកន្លះបរិមាត្រ និងផ្ទៃក្រឡានៃត្រីកោណនោះរៀងគ្នា ។
បើ r ជាកាំរង្វង់ចារឹកក្នុងត្រីកោណនោះ , បង្ហាញថា $S=pr$ ។

283. h_a,h_b,h_c ជារង្វាស់កម្ពស់ទាំងបីនៃត្រីកោណ ABC មួយ ដែលមានកាំរង្វង់ចារឹកក្នុង r ។
បង្ហាញថា $\dfrac{h_b}{h_a^2}+\dfrac{h_c}{h_b^2}+\dfrac{h_a}{h_c^2}\ge\dfrac{1}{r}$ ។

284. ពន្លាតនៃអនុគមន៍ពហុធា $P(x)=(1+2x)^{12}$ ប្រែក្លាយជារាង

$$P(x)=a_0+a_1x+a_2x^2+\cdots+a_{12}x^{12} \text{ ។}$$

រក $\max\{a_1,a_2,\dots,a_{12}\}$ ។

285. ក. បង្ហាញថា បើ x ជាចំនួនគត់ធម្មជាតិសេស នោះ តម្លៃរបស់កន្សោម $A=x^2+4x-5$ ជាពហុគុណនៃ 8 ។
ខ. រកចំនួនគត់ធម្មជាតិ x ដែល $65+x^2$ ជាការ៉េប្រាកដនៃចំនួនគត់ធម្មជាតិមួយ ។

286. បង្ហាញថា $\sqrt{6}$ ជាចំនួនអសនិទាន ។

287. បង្ហាញថា $\sqrt{2}+\sqrt{3}$ ជាចំនួនអសនិទាន ។

288. ដោះស្រាយសមីការ $\tan^2 x-\tan x\tan 3x=2$ ។

289. ដោះស្រាយសមីការ $\dfrac{\sin y+\sin 2y+\sin 3y}{\cos y+\cos 2y+\cos 3y}=\sqrt{3}$ ។

290. គេឲ្យ $f(x)=ax+b$ ដែល $x\in\mathbb{R}$ និង $a^2+b^2>0$ ។

បង្ហាញថា $\left(\int_0^{\frac{\pi}{2}} f(x)\sin x dx\right)^2+\left(\int_0^{\frac{\pi}{2}} f(x)\cos x dx\right)^2>0$ ។

291. ដោះស្រាយក្នុង $\mathbb{N}$ សមីការ ៖ $C_n^0+2C_n^1+2^2C_n^2+\cdots+2^nC_n^n=81$ ។

292. ពិនិត្យស្វ៊ីត ហ្វីបូណាស៊ី ៖

$$a_1=a_2=1 \text{ និង } a_{n+1}=a_n+a_{n-1}\ ,\ n\geq 2$$

បង្ហាញថាចំពោះគ្រប់ចំនួនគត់ធម្មជាតិ k,n ប្រភាគ ៖ $\dfrac{ka_{n+2}+a_n}{ka_{n+3}+a_{n+1}}$ មិនអាចសម្រួលបាន ។

293. គេមានត្រីកោណ ABC មួយមានមុំទាំងបីស្រួច ។ បង្ហាញថា ៖

$$\left(\sqrt{\tan A}-\sqrt{\cot\frac{A}{2}}\right)+\left(\sqrt{\tan B}-\sqrt{\cot\frac{B}{2}}\right)+\left(\sqrt{\tan C}-\sqrt{\cot\frac{C}{2}}\right)\geq\cot\frac{A}{2}\cot\frac{B}{2}\cot\frac{C}{2}-\tan A\tan B\tan C \text{ ។}$$

294. គេឲ្យសមីការ $ax^2+bx+c=0$, $(a\neq 0)$ មានឫសពីរ x_1 និង x_2 ដែល $x_1=x_2^2$ ។

បង្ហាញថា $b^3+a^2c+ac^2=3abc$ ។

295. គេឲ្យ m និង n ជាពីរចំនួនគត់វិជ្ជមាន ដែលផ្ទៀងផ្ទាត់ $\sqrt{7}-\dfrac{m}{n}>0$ ។

បង្ហាញថា $\sqrt{7}-\dfrac{m}{n}>\dfrac{1}{mn}$ ។

296. គេឲ្យ៥ ចំនួនមិនអវិជ្ជមាន a_1,a_2,a_3,a_4,a_5 ផ្ទៀងផ្ទាត់លក្ខខណ្ឌ ៖

$$a_1+a_2+a_3+a_4+a_5=1 \text{ ។}$$

រកតម្លៃអតិបរមារបស់កន្សោម $A=a_1a_2+a_2a_3+a_3a_4+a_4a_5$ ។

297. គេឲ្យស្វ៊ីត $u_1,u_2,u_3,\ldots,u_n,\ldots$ ផ្ទៀងផ្ទាត់ ៖

$$u_1=1, u_2=3$$
$$u_n=2u_{n-1}+u_{n-2}$$

បង្ហាញថា $u_n=1+2C_n^2+2^2C_n^4+2^3C_n^6+\cdots$ ។

298. គ្រប់ $n\in\mathbb{N}, n\geq 2$ ដោះស្រាយសមីការ ៖

$$2\cdot\sqrt[n]{(1+x)^2}+3\cdot\sqrt[n]{1-x^2}+\sqrt[n]{(1-x)^2}=0 \text{ ។}$$

299. បង្ហាញថា បើត្រីកោណ ABC មួយ មានជ្រុងទាំងបី a,b,c បង្កើតបានជាបីតួតគ្នានៃស្វ៊ីតនព្វន្តមួយ នោះ $B\leq\dfrac{\pi}{3}$ ។

300. គេសន្មតថាសមីការ $x^2-(a+d)x+(ad-bc)=0$ មានឫសពីរ គឺ x_1 និង x_2 ។
បង្ហាញថា x_1^3 និង x_2^3 ជាឫសរបស់សមីការ ៖

$$X^2-\left(a^3+d^3+3abc+3bcd\right)X+\left(ad-bc\right)^3=0$$ ៕

យើងខ្ញុំមានទទួលបង្រៀនគួរដល់ផ្ទះរបស់លោកអ្នក លើមុខវិជ្ជាគណិតវិទ្យា រូបវិទ្យា គីមីវិទ្យា ជីវវិទ្យា ភាសារខ្មែរ ពីមិនទាន់ចេះសោះ ដល់ថ្នាក់ទី ១២ និងថ្នាក់ត្រៀមប្រឡងសិស្សពូកែ, ប្រឡងអាហារូបករណ៍ ។
បើមានចំណាប់អារម្មណ៍សូមទាក់ទងតាមរយៈទូរសព្ទ ០១២ ៣៤៧ ៦២៤ ឬ អ៊ីម៉ែល ៖ pahen_hay@yahoo.com ។ សូមអរគុណ ។

ស្នើមិត្តអ្នកអានរកជាវនូវសៀវភៅ ៖

- *ទស្សនាវដ្ដីគណិតវិទ្យានៃកម្ពុជា និងការអប់រំ ចេញដល់លេខ ៩*
- *ក្បួនដោះទ័លក្រ ដោយ ហាក់ ឆៃហុក (១៩៧៩)*
- *ខ្ញុំមានជំងឺមហារីក តើលោកគ្រូពេទ្យអាចជួយខ្ញុំបានទេ? សៀវភៅនៃក្ដីសង្ឃឹម (អាង ផេង ជាន)*
- *និងសៀវភៅផ្សេងៗទៀត ។*

ដើម្បីជាអំណានបន្ថែម ។

លោកគ្រូ ស៊ិន ទូច ជាចាងហ្វាងទស្សនាវដ្ដីគណិតវិទ្យានៃកម្ពុជា និងការអប់រំ ,បានមានប្រសាសន៍ថា “ខ្ញុំត្រូវចំណាយប្រាក់យ៉ាងតិច ២០ ដុលារ ក្នុងមួយខែសម្រាប់ការទិញសៀវភៅផ្សេងៗមកជាអំណានបន្ថែម ហើយគិតជាមធ្យមក្នុងមួយថ្ងៃ ខ្ញុំសរសេរកំណាព្យបែបកំប្លែង ឬបែបគំនិតពិចារណា បានមួយទំព័រ អា៤ ដែលវាយជាកុំព្យូទ័ររួចជាស្រេច ” ។

សម្រាប់ខ្ញុំអ្នករៀបរៀងវិញ , គិតជាមធ្យមក្នុងមួយអាទិត្យ ត្រូវតែមានសៀវភៅថ្មី ១ក្បាល (អាចទិញពីផ្សារ ឬកូពី ឬ ព្រីនពីកុំព្យូទ័រ ឯកសារដែលដោនឡូតពីអីនធ័រណែត) ។ធ្វើលំហាត់ជាមធ្យម ៥ ក្នុងមួយថ្ងៃ ។ ចូលតាមបណ្ណាគារយ៉ាងតិច ១ កន្លែងក្នុង ១សប្ដាហ៍ ។ ពេលសម្រាកពីការធ្វើលំហាត់ ចូលចិត្ត ដេកអានសៀវភៅផ្សេង និងស្ដាប់ព័ត៌មាន នយោបាយ និង ចម្រៀង ។

ផ្នែកដំណោះស្រាយ

Solutions Part

201. ដោយមិនប្រើម៉ាស៊ីនគិតលេខ , ចូរបង្ហាញថា ៖ $\sqrt[3]{43} < \sqrt[3]{9} + \sqrt[3]{3} < \sqrt[3]{44}$ ។

ដំណោះស្រាយ

បង្ហាញថា ៖ $\sqrt[3]{43} < \sqrt[3]{9} + \sqrt[3]{3} < \sqrt[3]{44}$

តាង $x = \sqrt[3]{9} + \sqrt[3]{3}$ នាំឲ្យ $x^3 = 12 + 9x$

គេបាន , x គឺជាឫសរបស់សមីការ $f(x) = x^3 - 9x - 12 = 0$

យើងបាន , $f(x)$ គឺជាអនុគមន៍កំណត់គ្រប់ $x \in \mathbb{R}$ ហើយ $f\left(\sqrt[3]{9} + \sqrt[3]{3}\right) = 0$

គេបាន ៖ $f'(x) = 3x^2 - 9$

សិក្សាសញ្ញា $f'(x)$ គេបាន $f'(x) > 0$ កាលណា $x < -\sqrt{3} \vee x > \sqrt{3}$

នាំឲ្យ អនុគមន៍ $f(x)$ កើនកាលណា $x < -\sqrt{3} \vee x > \sqrt{3}$

ម្យ៉ាងទៀត $\sqrt[3]{44} > \sqrt[3]{43} > 3 > \sqrt{3}$

ហើយ $f\left(\sqrt[3]{43}\right) = 43 - 9\sqrt[3]{43} - 12 = 31 - 9\sqrt[3]{43} < 0$

$$f\left(\sqrt[3]{9} + \sqrt[3]{3}\right) = 0$$

$$f\left(\sqrt[3]{44}\right) > 0$$

ដូចនេះវិសមភាព $\sqrt[3]{43} < \sqrt[3]{9} + \sqrt[3]{3} < \sqrt[3]{44}$ ត្រូវបានស្រាយបញ្ជាក់ ។

202. គេឲ្យ ΔABC មានក្រឡាផ្ទៃ $S = 1$ ។ បង្ហាញថា ៖ $a^4 + b^4 + c^4 \geq 16$ ។

ដំណោះស្រាយ

បង្ហាញថា ៖ $a^4 + b^4 + c^4 \geq 16$

តាមរូបមន្តហេរ៉ុង , គេបាន ៖

$$S = \sqrt{p(p-a)(p-b)(p-c)}$$

$$S^2 = p(p-a)(p-b)(p-c) = 1$$

$$\frac{a+b+c}{2}\cdot\frac{b+c-a}{2}\cdot\frac{c+a-b}{2}\cdot\frac{a+b-c}{2}=1$$

$$\left((a+b)+c\right)\left((a+b)-c\right)\left(c-(a-b)\right)\left(c+(a-b)\right)=16$$

$$\left((a+b)^2-c^2\right)\left(c^2-(a-b)^2\right)=16$$

ដោយ $(a-b)^2>0$ **និង** $c^2-(a-b)^2<c^2$

$$a+b>c \quad \Rightarrow (a+b)^2>c^2 \qquad \Rightarrow (a+b)^2-c^2>0$$

គេបាន ៖

$$16\le\left((a+b)^2-c^2\right)c^2=\left(a^2+b^2+2ab-c^2\right)c^2$$

$$16\le\left(2a^2+2b^2-c^2\right)c^2$$

$$16\le 2a^2c^2+2b^2c^2-c^4$$

$$16\le\left(a^4+c^4\right)+\left(b^4+c^4\right)-c^4=a^4+b^4+c^4$$

នាំឲ្យ $a^4+b^4+c^4\ge 16$

សញ្ញាសមភាពកើតមានកាលណា ៖ $\begin{cases}a^2=b^2=c^2\\ a=b=c\end{cases}\Leftrightarrow a=b=c$

ដូចនេះវិសមភាព $a^4+b^4+c^4\ge 16$ **ត្រូវបានស្រាយបញ្ជាក់ ។**

203. **រកតម្លៃអតិបរមារបស់កន្សោម ៖** $A=\sin\alpha_1\cdot\sin\alpha_2\cdot\ldots\cdot\sin\alpha_{2013}$ **, បើគេដឹងថា ៖** $\tan\alpha_1\cdot\tan\alpha_2\cdot\ldots\cdot\tan\alpha_{2013}=1$ **។**

<u>*ដំណោះស្រាយ*</u>

រកតម្លៃអតិបរមារបស់កន្សោម ៖ $A=\sin\alpha_1\cdot\sin\alpha_2\cdot\ldots\cdot\sin\alpha_{2013}$

យើងមាន ៖ $\tan\alpha_1\cdot\tan\alpha_2\cdot\ldots\cdot\tan\alpha_{2013}=1$ **គេបាន ៖**

$$1\ge\sin 2\alpha_1\cdot\sin 2\alpha_2\cdot\ldots\cdot\sin 2\alpha_{2013}=2^{2013}\sin^2\alpha_1\cdot\sin^2\alpha_2\cdot\ldots\cdot\sin^2\alpha_{2013}$$

$$1\ge 2^{2013}A^2$$

$\Rightarrow A\le\sqrt{\dfrac{1}{2^{2013}}}$ **សញ្ញាសមភាពកើតមានកាលណា** $\alpha_1=\alpha_2=\cdots=\alpha_{2013}=\dfrac{\pi}{4}$

ដូចនេះតម្លៃអតិបរមារបស់កន្សោម A **គឺ** $\max A=\sqrt{\dfrac{1}{2^{2013}}}$ **កាលណា**

$\alpha_1=\alpha_2=\cdots=\alpha_{2013}=\dfrac{\pi}{4}$ **។**

204. សុខជ្រើសរើសបួនចំនួនផ្សេងគ្នាចេញអំពីសំណុំ $\{1,2,3,4,5,6,7\}$ ដែលមានផលបូកស្មើនឹង 11 ។ បើ L គឺជាចំនួនដែលធំបំផុតក្នុងចំណោមចំនួនទាំងបួននោះ ។ ចូរកំណត់តម្លៃនៃ L ។

ដំណោះស្រាយ

របៀបទី ១

កំណត់តម្លៃនៃ L

យើងសម្គាល់ថា ផលបូកនៃបួនចំនួនគត់វិជ្ជមានតូចបំផុតនៅក្នុងសំណុំខាងលើគឺ ៖

$$1+2+3+4=10$$

គេទាញបាន, $1+2+3+5=11$ ។ ចំនួនគត់វិជ្ជមានធំបំផុតនៅក្នុងផលបូកនេះគឺ 5 ។

ដូច្នេះ $L=5$ ត្រូវបានកំណត់ ។

របៀបទី ២

កំណត់តម្លៃនៃ L

ដោយ L គឺជាចំនួនដែលធំបំផុតនៃបួនចំនួនដែលជ្រើសចេញពី$\{1,2,3,4,5,6,7\}$, $L\geq 4$ ។

ដូច្នេះ, L គឺអាចស្មើនឹងចំនួនមួយ ក្នុងចំណោមចំនួន $4,5,6$ និង 7 ។

បើ $L=7$ នោះផលបូកតូចបំផុតដែលអាចមាននៃបួនចំនួននោះគឺ $1+2+3+4=13>11$,

ដូច្នេះ $L\neq 7$ ។

ដូចគ្នាដែរ, បើ $L=6$ នៅតម្លៃតូចបំផុតនៃផលបូកចំនួនទាំងបួននោះគឺ

$1+2+3+6=12>11$ ។ ដូច្នេះ $L\neq 6$ ។

ដូចគ្នាដែរ, បើ $L=5$ នៅតម្លៃតូចបំផុតនៃផលបូកចំនួនទាំងបួននោះគឺ

$1+2+3+5=11$ (យកបាន)

ដូចនេះ $L=5$ ត្រូវបានកំណត់ ។

205. ដោះស្រាយសមីការ ៖

ក. $\left(2\cos 3x+6\cos x+1\right)^3=162\cos x-27$

ខ. $3^{2013x+3\cos x}-3^{2013x+4\cos^3 x}-3\cos 3x=0$

គ. $(\sin x)\sqrt[2012]{\sin^2 x+2012}-(\cos x+1)\sqrt[2012]{\cos^2 x+2\cos x+2013}=\cos x-\sin x+1$

ឃ. $\tan x=\cos^2\left(2x+\dfrac{5\pi}{12}\right)+\sin^2\left(2x+\dfrac{5\pi}{12}\right)+\sin x\sin\left(3x+\dfrac{5\pi}{6}\right)$

ដំណោះស្រាយ

ដោះស្រាយសមីការ ៖

ក. $\left(2\cos 3x+6\cos x+1\right)^3=162\cos x-27$

តាង $t=2\cos x$, $-2\leq t\leq 2$

នោះសមីការក្លាយទៅជា ៖ $t^3+1=3\sqrt[3]{3t-1}$

តាង $u=\sqrt[3]{3t-1}$ គេបាន ប្រព័ន្ធសមីការ ៖

$$\begin{cases} t^3 = 3u - 1 & (1) \\ u^3 = 3t - 1 & (2) \end{cases}$$

យក $(1)-(2)$ **គេបាន ៖**

$$t^3 - u^3 = 3(u-t)$$
$$(t-u)(t^2+tu+u^2)+3(t-u)=0$$
$$(t-u)(t^2+tu+u^2+3)=0$$

ដោយ $t^2+tu+u^2+3>0$ **, នោះ គេបាន ៖**

$$t-u=0 \Rightarrow t=u$$
$$t^3-3t+1=0$$
$$(2\cos x)^3-3(2\cos x)+1=0$$
$$8\cos^3 x-6\cos x+1=0$$
$$2\cos 3x+1=0$$
$$\cos 3x=-\frac{1}{2}$$
$$3x=\pm\frac{2\pi}{3}+2k\pi \quad , k\in\mathbb{Z}$$
$$x=\pm\frac{2\pi}{9}+\frac{2k\pi}{3} \quad , k\in\mathbb{Z}$$

ដូចនេះសមីការមានឫស $x=\pm\frac{2\pi}{9}+\frac{2k\pi}{3} \quad , k\in\mathbb{Z}$ **។**

ខ. $3^{2013x+3\cos x}-3^{2013x+4\cos^3 x}-3\cos 3x=0$

សមីការដែលឲ្យសមមូល ៖

$$3^{2013x+3\cos x}-3^{2013x+4\cos^3 x}=3(4\cos^3 x-3\cos x)$$
$$3^{2013x+3\cos x}+3(2013x+3\cos x)=3^{2013x+4\cos^3 x}+3(2013x+4\cos^3 x)$$

តាង $f(t)=3^t+3t \quad , t\in\mathbb{R}$ **គេបាន ៖**

$$f'(t)=3^t\ln 3+3>0$$

នោះ $f(t)$ **ជាអនុគមន៍កើនជានិច្ច មានន័យថា** $f(t)$ **ជាអនុគមន៍ប្រកាន់**

គេបាន ៖

$$3^{2013x+3\cos x}+3(2013x+3\cos x)=3^{2013x+4\cos^3 x}+3(2013x+4\cos^3 x)$$
$$f(2013x+3\cos x)=f(2013x+4\cos^3 x)$$
$$2013x+3\cos x=2013x+4\cos^3 x$$
$$3\cos x-4\cos^3 x=0$$
$$\cos 3x=0$$
$$3x=\frac{\pi}{2}+k\pi \quad , k\in\mathbb{Z}$$
$$x=\frac{\pi}{6}+\frac{k\pi}{3} \quad , k\in\mathbb{Z}$$

ដូចនេះសមីការមានឫស $x=\frac{\pi}{6}+\frac{k\pi}{3} \quad , k\in\mathbb{Z}$ **។**

គ. $(\sin x)\sqrt[2012]{\sin^2 x+2012}-(\cos x+1)\sqrt[2012]{\cos^2 x+2\cos x+2013}=\cos x-\sin x+1$

សមីការដែលឲ្យសមមូល ៖

$$(\sin x)\sqrt[2012]{\sin^2 x+2012}+\sin x=(\cos x+1)\sqrt[2012]{\cos^2 x+2\cos x+2013}+\cos x+1$$

$$(\sin x)\sqrt[2012]{\sin^2 x+2012}+\sin x=(\cos x+1)\sqrt[2012]{(\cos x+1)^2+2012}+\cos x+1$$

តាង $f(t)=t+t\sqrt[2012]{t^2+2012}$, $t\in\mathbb{R}$ **គេបាន ៖**

$$f'(t)=1+\sqrt[2012]{t^2+2012}+\left(\frac{t^2}{1006}\right)\left(\frac{1}{\sqrt[2012]{(t^2+2012)^{2011}}}\right)>0$$

នោះ $f(t)$ **ជាអនុគមន៍កើនជានិច្ច មានន័យថា** $f(t)$ **ជាអនុគមន៍ប្រកាន់**

គេបាន ៖

$$(\sin x)\sqrt[2012]{\sin^2 x+2012}+\sin x=(\cos x+1)\sqrt[2012]{(\cos x+1)^2+2012}+\cos x+1$$

$$f(\sin x)=f(\cos x+1)$$

$$\sin x=\cos x+1$$

$$\left[\begin{array}{l} x=\dfrac{\pi}{2}+2k\pi \\ x=\pi+2k\pi \end{array}\right. , k\in\mathbb{Z}$$

ដូចនេះសមីការមានឫស $x=\dfrac{\pi}{2}+2k\pi$, $x=\pi+2k\pi$, $(k\in\mathbb{Z})$ **។**

ឃ. $\tan x=\cos^2\left(2x+\dfrac{5\pi}{12}\right)+\sin^2\left(2x+\dfrac{5\pi}{12}\right)+\sin x\sin\left(3x+\dfrac{5\pi}{6}\right)$

យើងមាន ៖

$$\begin{aligned}\sin(a+b)\sin(a-b)&=(\sin a\cos b+\sin b\cos a)(\sin a\cos b-\sin b\cos a)\\&=\sin^2 a\cos^2 b-\sin^2 b\cos^2 a\\&=(1-\cos^2 a)(1-\sin^2 b)-\sin^2 b\cos^2 a\\&=1-\sin^2 b-\cos^2 a+\cos^2 a\sin^2 b-\sin^2 b\cos^2 a\\&=1-\sin^2 b-\cos^2 a\end{aligned}$$

នាំឲ្យគេបាន ៖ $\sin^2 b\cos^2 a+\sin(a+b)\sin(a-b)=1 \qquad (1)$

តាង $a=2x+\dfrac{5\pi}{12}$ **និង** $b=x+\dfrac{5\pi}{12}$

គេបាន សមីការ (1) **ទៅជា ៖**

$$\sin^2\left(x+\frac{5\pi}{12}\right)+\cos^2\left(2x+\frac{5\pi}{12}\right)+\sin x\sin\left(3x+\frac{5\pi}{6}\right)=1$$

នោះសមីការដែលត្រូវដោះស្រាយក្លាយទៅជា ៖

$$\tan x=1$$

$$x=\frac{\pi}{4}+k\pi \ , k\in\mathbb{Z}$$

ដូចនេះឫសរបស់សមីការគឺ $x=\dfrac{\pi}{4}+k\pi$, $k\in\mathbb{Z}$ **។**

206. x, y **និង** z **គឺជាចំនួនពិតធំជាង** 1 **ហើយ** w **គឺជាចំនួនពិតវិជ្ជមានមួយ ។**

បើ $\log_x w = 24, \log_y w = 40$ **និង** $\log_{xyz} w = 12$ **។ រកតម្លៃនៃ** $\log_z w$ **។**

ដំណោះស្រាយ

រកតម្លៃនៃ $\log_z w$

យើងមាន $\log_x w = 24, \log_y w = 40$ **និង** $\log_{xyz} w = 12$ **គេបាន ៖**

$$\begin{aligned}
12 &= \log_{xyz} w \\
&= \frac{\log w}{\log xyz} \\
&= \frac{\log w}{\log x + \log y + \log z} \\
&= \frac{1}{\frac{\log x + \log y + \log z}{\log w}} \\
&= \frac{1}{\frac{\log x}{\log w} + \frac{\log y}{\log w} + \frac{\log y}{\log w}} \\
&= \frac{1}{\log_w x + \log_w y + \log_w z} \\
&= \frac{1}{\frac{1}{\log_x w} + \frac{1}{\log_y w} + \frac{1}{\log_z w}}
\end{aligned}$$

$$12 = \frac{1}{\frac{1}{24} + \frac{1}{40} + \frac{1}{\log_z w}}$$

$$\frac{1}{24} + \frac{1}{40} + \frac{1}{\log_z w} = \frac{1}{12}$$

$$\frac{1}{\log_z w} = \frac{1}{12} - \frac{1}{24} - \frac{1}{40}$$

$$\frac{1}{\log_z w} = \frac{1}{24} - \frac{1}{40} = \frac{5-3}{120}$$

$$\frac{1}{\log_z w} = \frac{1}{60}$$

$$\log_z w = 60$$

ដូចនេះ $\log_z w = 60$ **ត្រូវបានគណនា ។**

207. **ឧបមាថាពន្លាតកន្សោម ៖**

$\left(1 - 3x + 4x^2\right)^{502}\left(1 + 3x - 4x^2\right)^{504} = a_n x^n + a_{n-1}x^{n-1} + \cdots + a_1 x + a_0$ **។**

ក. តើ n **ស្មើនឹងប៉ុន្មាន ?**

ខ. គណនាផលបូក $S = a_{2012} + a_{2011} + \cdots + a_1 + a_0$ **។**

ដំណោះស្រាយ

ក. តើ n ស្មើនឹងប៉ុន្មាន ?

យើងមាន $\left(1-3x+4x^2\right)^{502}\left(1+3x-4x^2\right)^{504}=a_nx^n+a_{n-1}x^{n-1}+\cdots+a_1x+a_0$ **គេបាន ៖**

ដឺក្រេរបស់ពហុធា $\left(1-3x+4x^2\right)^{502}\left(1+3x-4x^2\right)^{504}$ **គឺ ៖** $2\times502+2\times504=2012$

ដូចនេះ $n=2012$ **ត្រូវបានកំណត់ ។**

ខ. គណនាផលបូក $S=a_{2012}+a_{2011}+\cdots+a_1+a_0$

ដោយ $n=2012$ **គេបាន ៖**

$$\left(1-3x+4x^2\right)^{502}\left(1+3x-4x^2\right)^{504}=a_{2012}x^{2012}+a_{2011}x^{2011}+\cdots+a_1x+a_0$$

យក $n=1$ **គេបាន ៖**

$$a_{2012}1^{2012}+a_{2011}1^{2011}+\cdots+a_11+a_0=(1-3+4)^{502}(1+3-4)^{504}$$
$$S=a_{2012}+a_{2011}+\cdots+a_1+a_0=\left(2^{502}\right)\left(0^{504}\right)$$
$$S=0$$

ដូចនេះ $S=a_{2012}+a_{2011}+\cdots+a_1+a_0=0$ **ត្រូវបានគណនា ។**

208. ដោះស្រាយប្រព័ន្ធសមីការ ៖

$$\lfloor x\rfloor+3\{y\}=3.9$$
$$\{x\}+3\lfloor y\rfloor=3.4$$

ដំណោះស្រាយ

ដោះស្រាយប្រព័ន្ធសមីការ

យើងមានប្រព័ន្ធសមីការ ៖

$$\lfloor x\rfloor+3\{y\}=3.9$$
$$\{x\}+3\lfloor y\rfloor=3.4$$

តាង $x=a+u$ **និង** $y=b+v$ **ដែល** a **និង** b **ជាចំនួនគត់ និង** $0\le u,v<1$

នោះប្រព័ន្ធសមីការក្លាយទៅជា ៖

$$a+3v=3.9$$
$$u+3b=3.4$$

បូកអង្គ និងអង្គនៃសមីការទាំងពីរ , គេបាន ៖

$$(a+u)+3(b+v)=7.3$$
$$x+3y=7.3$$

ម្យ៉ាងទៀត ៖

$$3b \le 3.4 = u + 3b < 3b + 1$$
$$\Rightarrow 0.8 < b < 1.2$$

ដោយ b ជាចំនួនគត់ នោះ $b = 1$ គេបាន $u = 0.4$

ស្រដៀងគ្នាដែរ ៖

$$a \le 3.9 = a + 3v < a + 3$$
$$\Rightarrow 0.9 < a < 3.9$$

ដោយ a ជាចំនួនគត់ នោះ $a = 1, 2, 3$ គេបាន $3v = 3.9 - a$ នាំឲ្យ $v = \frac{29}{30}, \frac{19}{30}, 0.3$

ដូចនេះ ប្រព័ន្ធសមីការខាងលើមានគូចម្លើយ $\left(\frac{7}{5}, \frac{59}{30}\right), \left(\frac{12}{5}, \frac{49}{30}\right)$ និង $\left(\frac{17}{5}, \frac{39}{30}\right) = (3.4, 1.3)$ ។

209. យើងមាន ABC ជាត្រីកោណសមបាតដែល $AB = AC$ ។ សន្មតថាកន្លះបន្ទាត់ពុះនៃមុំ $\angle B$ កាត់ជ្រុង AC ត្រង់ D និង $BC = BD + AD$ ។ កំណត់តម្លៃ $\angle A$ ។

ដំណោះស្រាយ

កំណត់តម្លៃ $\angle A$

តាង $\alpha = \angle A, \beta = \frac{\pi - \alpha}{4}$ និងសន្មតថា $AB = 1$

នោះតាមទ្រឹស្តីបទស៊ីនុស , គេបាន ៖

$$BC = \frac{\sin\alpha}{\sin 2\beta}, \ BD = \frac{\sin\alpha}{\sin 3\beta}, \ AD = \frac{\sin\beta}{\sin 3\beta}$$

ដូច្នេះយើងនឹងត្រូវដោះស្រាយសមីការ ៖

$$\sin(\pi - 4\beta)\sin 3\beta = \left(\sin(\pi - 4\beta) + \sin\beta\right)\sin 2\beta$$

ដោយប្រើរូបមន្តផលបូក ទៅផលគុណ , យើងបាន ៖

$$\cos\beta - \cos 7\beta = \cos 2\beta - \cos 6\beta + \cos\beta - \cos 3\beta$$
$$\cos 3\beta - \cos 7\beta = \cos 2\beta - \cos 6\beta$$
$$\sin 2\beta \sin 5\beta = \sin 2\beta \sin 4\beta$$
$$\sin 5\beta = \sin 4\beta$$
$$9\beta = \pi$$
$$\beta = \frac{\pi}{9}$$

គេបាន $\angle A = \alpha = \pi - 4\beta = \pi - 4 \cdot \frac{\pi}{9} = \frac{5\pi}{9}$

ដូចនេះ $\angle A = \frac{5\pi}{9}$ ត្រូវបានគណនា ។

210. ស្រមោចមួយស្ថិតនៅត្រង់កំពូល V នៃគូបមួយដែលមានរង្វាស់ជ្រុងនីមួយៗ $1m$ ។ ស្រមោចនោះត្រូវផ្លាស់ទីតាមជ្រុងនីមួយៗរបស់គូប និងត្រឡប់មកកំពូល V វិញ ដោយមិនឆ្លងកាត់តាមចំណុចណាមួយពីរដងឡើយ ។ រកប្រវែងវែងបំផុតនៃគន្លង ។



<u>ដំណោះស្រាយ</u>

ប្រវែងវែងបំផុតនៃគន្លងគឺ $8m$ ។(សាកដោះស្រាយដោយខ្លួនឯង)

211. ដោះស្រាយសមីការខាងក្រោម ៖

ក. $\sqrt{x-2\sqrt{x-1}}+\sqrt{x+3-4\sqrt{x-1}}=1$

ខ. $\sqrt{1-x}=\sqrt{6-x}-\sqrt{-5-2x}$ ។

<u>ដំណោះស្រាយ</u>

ដោះស្រាយសមីការ ៖

ក. $\sqrt{x-2\sqrt{x-1}}+\sqrt{x+3-4\sqrt{x-1}}=1$

លក្ខខណ្ឌ , សមីការខាងលើមានន័យកាលណា ៖

$$\begin{cases} x-1\geq 0 & (1) \\ x-2\sqrt{x-1}\geq 0 & (2) \\ x+3-4\sqrt{x-1}\geq 9 & (3) \end{cases}$$

តាម $(1)\Leftrightarrow x\geq 1$ នោះគេបាន $(2)\Leftrightarrow x-2\sqrt{x-1}\geq 1-2\cdot 0>0$ ពិត

និង $(3)\Leftrightarrow x+3-4\sqrt{x-1}\geq 1+3-4\cdot 0>0$ ពិត

ដូច្នេះ គេបានលក្ខខណ្ឌ $x\geq 1$ ។

គេបាន , សមីការក្លាយទៅជា ៖

$$\sqrt{\left(\sqrt{x-1}-1\right)^2}+\sqrt{\left(\sqrt{x-1}-2\right)^2}=1$$

$$\left|\sqrt{x-1}-1\right|+\left|\sqrt{x-1}-2\right|=1 \qquad (*)$$

- បើ $\sqrt{x-1}<1$ នោះសមីការ $(*)\Leftrightarrow -\left(\sqrt{x-1}-1\right)-\left(\sqrt{x-1}-2\right)=1$

$$-2\sqrt{x-1}+3=1$$

$\sqrt{x-1}=1$ មិនពិត

- បើ $1\le\sqrt{x-1}\le 2\Leftrightarrow 2\le x\le 5$ នោះសមីការ $(*)\Leftrightarrow\left(\sqrt{x-1}-1\right)-\left(\sqrt{x-1}-2\right)=1$
  $\Leftrightarrow 1=1$ ផ្ទៀងផ្ទាត់ជានិច្ច
- បើ $2<\sqrt{x-1}$ នោះសមីការ $(*)\Leftrightarrow\left(\sqrt{x-1}-1\right)+\left(\sqrt{x-1}-2\right)=1$
  $$2\sqrt{x-1}-3=1$$
  $\sqrt{x-1}=2$ មិនពិត

ដូចនេះសរុបមកចម្លើយរបស់សមីការគឺ $x\in[2,5]$ ។

ខ. $\sqrt{1-x}=\sqrt{6-x}-\sqrt{-5-2x}$

លក្ខខណ្ឌ , សមីការខាងលើមានន័យកាលណា ៖

$$\begin{cases}1-x\ge 0\\ 6-x\ge 0\\ -5-2x\ge 0\end{cases}\Leftrightarrow\begin{cases}x\le 1\\ x\le 6\\ x\le-\dfrac{5}{2}\end{cases}\Leftrightarrow x\le-\frac{5}{2}$$

គេបាន , សមីការក្លាយទៅជា ៖

$$\sqrt{1-x}+\sqrt{-5-2x}=\sqrt{6-x}$$
$$1-x+(-5-2x)+2\sqrt{(1-x)(-5-2x)}=6-x$$
$$\sqrt{(1-x)(-5-2x)}=x+5$$
$$(1-x)(-5-2x)=x^2+10x+25$$
$$-5-2x+5x+2x^2=x^2+10x+25$$
$$x^2-7x-30=0$$
$$x_{1,2}=\frac{-(-7)\pm\sqrt{(-7)^2-4(1)(-30)}}{2\cdot 1}=\frac{7\pm 13}{2}=\left[\begin{array}{l}10\\-3\end{array}\right.$$

តែតាមលក្ខខណ្ឌ $x\le-\dfrac{5}{2}$ ដូច្នេះ $x=10$ មិនយក

ដូចនេះចម្លើយរបស់សមីការគឺ $x=-3$ ត្រូវបានដោះស្រាយ ។

212. គណនាមាឌនៃសូលីតខាងក្រោម គិតជា cm^3 ។ សូលីតនេះគឺជាប្រអប់ដែលមានប្រហោងខាងក្នុងគឺជាការ៉េ ។ រង្វាស់នៅក្នុងរូបគិតជា cm ។



ដំណោះស្រាយ

គណនាមាឌនៃសូលីត

មាឌនៃសូលីតត្រូវយកមាឌប្រលេពីប៉ែតកែងធំដកនឹងមាឌប្រលេពីប៉ែតកែងតូច(ប្រហោង)

មាឌនៃប្រលេពីប៉ែតកែងធំគឺ ៖ $V_1=(6cm)(6cm)(5cm)=180\,cm^3$

មាឌនៃប្រលេពីប៉ែតកែងតូចគឺ ៖ $V_2=(4cm)(4cm)(5cm)=80\,cm^3$

គេបាន , មាឌនៃសូលីត គឺ ៖ $V=V_1-V_2=180\,cm^3-80\,cm^3=100\,cm^3$ ។

ដូចនេះ មាឌនៃសូលីត គឺ $100\,cm^3$ ត្រូវបានកំណត់ ។

213. បង្ហាញថា ចំពោះគ្រប់ចំនួនពិតវិជ្ជមាន a,b,c គេបាន ៖

$$\frac{1}{a^3+b^3+abc}+\frac{1}{b^3+c^3+abc}+\frac{1}{c^3+a^3+abc}\le\frac{1}{abc}$$ ។

ដំណោះស្រាយ

បង្ហាញវិសមភាព $\frac{1}{a^3+b^3+abc}+\frac{1}{b^3+c^3+abc}+\frac{1}{c^3+a^3+abc}\le\frac{1}{abc}$

ចំពោះគ្រប់ចំនួនពិតវិជ្ជមាន a,b,c យើងមាន ៖

$$a^2+b^2\ge 2ab\Rightarrow a^3+b^3\ge ab(a+b)$$

នាំឲ្យ $\frac{abc}{a^3+b^3+abc}\le\frac{abc}{ab(a+b)+abc}=\frac{c}{a+b+c}$ (១)

ដូចគ្នាដែរ $\frac{abc}{b^3+c^3+abc}\le\frac{abc}{bc(b+c)+abc}=\frac{a}{a+b+c}$ (២)

និង $\frac{abc}{c^3+a^3+abc}\le\frac{abc}{ca(c+a)+abc}=\frac{b}{a+b+c}$ (៣)

បូកអង្គ និងអង្គ នៃ (១) , (២) និង (៣) គេបាន ៖

$$\frac{abc}{a^3+b^3+abc}+\frac{abc}{b^3+c^3+abc}+\frac{abc}{c^3+a^3+abc}\le\frac{c}{a+b+c}+\frac{a}{a+b+c}+\frac{b}{a+b+c}$$

$$\frac{abc}{a^3+b^3+abc}+\frac{abc}{b^3+c^3+abc}+\frac{abc}{c^3+a^3+abc}\le 1$$

$$\frac{1}{a^3+b^3+abc}+\frac{1}{b^3+c^3+abc}+\frac{1}{c^3+a^3+abc}\le\frac{1}{abc}$$

សមភាពកើតមានកាលណា ៖ $a=b=c$

ដូចនេះ វិសមភាព $\frac{1}{a^3+b^3+abc}+\frac{1}{b^3+c^3+abc}+\frac{1}{c^3+a^3+abc}\le\frac{1}{abc}$ ត្រូវបានបង្ហាញ ។

214. រង្វង់ $C: x^2+y^2+kx+(1+k)y-(k+1)=0$ កាត់តាមពីរចំណុចជានិច្ចគ្រប់តម្លៃ k ។

១. រកកូអរដោនេនៃពីរចំណុចនោះ ។

២. រកតម្លៃអប្បបរមានៃកាំរបស់រង្វង់នោះ ។

ដំណោះស្រាយ

១. រកកូអរដោនេនៃពីរចំណុច

យើងមានសមីការរង្វង់ $C: x^2+y^2+kx+(1+k)y-(k+1)=0$ គេបាន ៖

$\left(x^2+y^2+y-1\right)+k\left(x+y-1\right)=0$ គ្រប់តម្លៃ k , យើងបាន

$$\begin{cases} x^2+y^2+y-1=0 \\ x+y-1=0 \end{cases}$$

$$\begin{cases} x^2+y^2+y-1=0 & (1) \\ y=1-x & (2) \end{cases}$$

ជួសសមីការ (2) ក្នុងសមីការ (1) គេបាន ៖

$$x^2+(1-x)^2-x=0$$

$$x^2+1-2x+x^2-x=0$$

$$2x^2-3x+1=0$$

$$x_1=1, x_2=\frac{1}{2}$$

បើ $x=1$ នោះ $(2): y=0$

បើ $x=\frac{1}{2}$ នោះ $(2): y=\frac{1}{2}$

ដូចនេះកូអរដោនេនៃពីរចំណុចនោះគឺ $(1,0)$ និង $\left(\frac{1}{2},\frac{1}{2}\right)$ ។

២. រកតម្លៃអប្បបរមានៃកាំរបស់រង្វង់នោះ

សមីការរង្វង់ $C: x^2+y^2+kx+(1+k)y-(k+1)=0$ សមមូល

$$\left(x^2+kx\right)+\left(y^2+(1+k)y\right)-(k+1)=0$$

$$\left(x+\frac{k}{2}\right)^2+\left(y+\frac{1+k}{2}\right)^2-\frac{k^2}{4}-\frac{(1+k)^2}{4}-(k+1)=0$$

$$\left(x+\frac{k}{2}\right)^2+\left(y+\frac{1+k}{2}\right)^2=\frac{k^2+1+2k+k^2+4k+4}{4}$$

$$\left(x+\frac{k}{2}\right)^2+\left(y+\frac{1+k}{2}\right)^2=\frac{2k^2+6k+5}{4}$$

កាំនៃរង្វង់ គឺ $r=\sqrt{\frac{2k^2+6k+5}{4}}$ គេបាន ៖

$$r=\sqrt{\frac{2k^2+6k+5}{4}}=\frac{\sqrt{2\left(k^2+3k\right)+5}}{2}$$

$$r=\frac{\sqrt{2\left(k+\frac{3}{2}\right)^2+5-\frac{9}{4}}}{2}=\frac{\sqrt{2\left(k+\frac{3}{2}\right)^2+\frac{11}{4}}}{2}$$

$$r\geq\frac{\sqrt{\frac{11}{4}}}{2}=\frac{\sqrt{11}}{4}$$

ដូចនេះតម្លៃអប្បបរមានៃកាំរបស់រង្វង់នោះ គឺ $\frac{\sqrt{11}}{4}$ (ឯកតាប្រវែង) កាលណា $k=-\frac{3}{2}$ ។

215. តាង $x>0$, $y>0$, $xy=8$ និង $P=2\left(\log_2 x\right)^2+\left(\log_2 y\right)^2$ ។

១. តាង $X=\log_2 x$ ។ សរសេរកន្សោម P ទៅជាអនុគមន៍នៃ X ។

២. រកតម្លៃអប្បបរមានៃ P ។

ដំណោះស្រាយ

១. សរសេរកន្សោម P ទៅជាអនុគមន៍នៃ X

យើងមាន $P=2\left(\log_2 x\right)^2+\left(\log_2 y\right)^2$ និង $X=\log_2 x$ គ្រប់ $x>0$, $y>0$, $xy=8$

គេបាន ៖

$$X=\log_2 x=\log_2\left(\frac{8}{y}\right)=\log_2 8-\log_2 y=3-\log_2 y$$

$$\Rightarrow \log_2 y=3-X$$

យើងបាន ៖

$$P=2X^2+\left(3-X\right)^2=2X^2+9-6X+X^2$$

$$P=3X^2-6X+9$$

ដូចនេះ $P=3X^2-6X+9$ ត្រូវបានសរសេរទៅជាអនុគមន៍នៃ X ។

២. រកតម្លៃអប្បបរមានៃ P

យើងមាន $P=3X^2-6X+9$ គេបាន ៖

$$P=3\left(X^2-2X+3\right)=3\left(\left(X-1\right)^2+2\right)\geq 3\cdot 2=6$$

សមភាពកើតមានកាលណា $X-1=0\Leftrightarrow X=1\Leftrightarrow \log_2 x=1\Leftrightarrow x=2$ និង $y=\frac{8}{x}=4$

ដូចនេះតម្លៃអប្បបរមានៃ P គឺ $P_{\min}=6$ កាលណា $x=2$ និង $y=4$ ។

216. គេមានបួនចំណុច A,B,C និង D ឋិតនៅលើកន្លះរង្វង់មួយដូចរូប ។ កាំនៃកន្លះរង្វង់នេះគឺ 1 ឯកតា ហើយផ្ចិតរបស់វាគឺ O ។ CD គឺជាអង្កត់ផ្ចិត និងសមាមាត្រនៃក្រឡាផ្ទៃត្រីកោណគឺ ៖ $S_{\Delta OAB}:S_{\Delta OBC}:S_{\Delta OCD}=1:2:2$ ។

១. តាង $\alpha=\angle AOB$ និង $\beta=\angle BOC$ ។ រក $\sin\alpha:\sin\beta$ ។

២. រកក្រឡាផ្ទៃនៃចតុកោណ $ABCD$ ។



ដំណោះស្រាយ

១. រក $\sin\alpha:\sin\beta$

ដោយអនុវត្តន៍ទ្រឹស្តីបទស៊ីនុស , គេបាន ៖

$$S_{\Delta AOB}=\frac{1}{2}(OA\cdot OB)\sin\alpha=\frac{1}{2}\sin\alpha$$ (ព្រោះកាំរង្វង់ $OA=OB=1$)

$$S_{\Delta BOC}=\frac{1}{2}(OB\cdot OC)\sin\beta=\frac{1}{2}\sin\beta$$ (ព្រោះកាំរង្វង់ $OB=OC=1$)

ហើយតាមបំរាប់ , $S_{\Delta AOB}:S_{\Delta BOC}=1:2$ គេបាន ៖

$$\frac{1}{2}\sin\alpha:\frac{1}{2}\sin\beta=1:2$$

$$\sin\alpha:\sin\beta=1:2$$

ដូចនេះ $\sin\alpha:\sin\beta=1:2$ ត្រូវបានរក ។

២. រកក្រឡាផ្ទៃនៃចតុកោណ $ABCD$

គេបាន ៖ $S_{ABCD}=S_{\Delta AOB}+S_{\Delta BOC}+S_{\Delta COD}$

តែ $S_{\Delta AOB}:S_{\Delta BOC}:S_{\Delta COD}=1:2:2\Rightarrow 2S_{\Delta AOB}=S_{\Delta BOC}=S_{\Delta COD}$

យើងបាន ៖ $S_{ABCD}=5S_{\Delta AOB}=5\left(\frac{1}{2}\sin\alpha\right)=\frac{5}{2}\sin\alpha$

យើងមាន $S_{\Delta COD}=\frac{1}{2}(OC\cdot OD)\sin\left(180^o-(\alpha+\beta)\right)=\frac{1}{2}\sin(\alpha+\beta)$

ដោយ $S_{\Delta BOC}=S_{\Delta COD}$ គេបាន $\frac{1}{2}\sin\beta=\frac{1}{2}\sin(\alpha+\beta)$

$$\sin\beta=\sin(\alpha+\beta)$$

$$\beta=180^o-(\alpha+\beta)\quad,\alpha\neq 0$$

$$\beta=\frac{180^o-\alpha}{2}$$

ហើយ $\frac{\sin\alpha}{1}=\frac{\sin\beta}{2}\Leftrightarrow\frac{\sin\alpha}{1}=\frac{\sin\left(90^o-\frac{\alpha}{2}\right)}{2}$

$$2\sin\frac{\alpha}{2}\cos\frac{\alpha}{2}=\frac{1}{2}\cos\frac{\alpha}{2}\quad,\ \cos\frac{\alpha}{2}\neq 0$$

$$\sin\frac{\alpha}{2}=\frac{1}{4}$$

$$\cos\frac{\alpha}{2}=\sqrt{1-\sin^2\frac{\alpha}{2}}=\sqrt{1-\frac{1}{16}}=\frac{\sqrt{15}}{4}\ ,\ 0^o<\frac{\alpha}{2}<90^o$$

នាំឲ្យ $\sin\alpha=2\sin\frac{\alpha}{2}\cos\frac{\alpha}{2}=2\left(\frac{1}{4}\right)\left(\frac{\sqrt{15}}{4}\right)=\frac{\sqrt{15}}{8}$

គេបាន ៖ $S_{ABCD}=\frac{5}{2}\left(\frac{\sqrt{15}}{8}\right)=\frac{5\sqrt{15}}{16}$ ឯកតាផ្ទៃ ។

ដូចនេះផ្ទៃក្រឡានៃចតុកោណ $ABCD$ គឺ $\frac{5\sqrt{15}}{16}$ ឯកតាផ្ទៃ ។

217. មានចំណុច A មួយនៅលើខ្សែកោង $C: x^2+y^2-2x-4=0$ ។ បើបន្ទាត់ប៉ះនឹង C ត្រង់ A កាត់តាមចំណុច $P(4,3)$ ។ ចូរគណនាប្រវែង AP ។

ដំណោះស្រាយ

គណនាប្រវែងនៃ AP

យើងមានសមីការខ្សែកោង $C: x^2+y^2-2x-4=0$ គេបាន ៖

$$(x^2-2x)+y^2=4$$

$$(x-1)^2+y^2=5$$

គេបាន C គឺជារង្វង់ដែលមានផ្ចិត $I(1,0)$ និងកាំ $r=\sqrt{5}$ ឯកតា ។

គេបាន បន្ទាត់ AP កែងនឹងកាំរង្វង់ , មានន័យថាត្រីកោណ IAP ជាត្រីកោណកែងត្រង់ A ហើយមាន $P(3,4)$ និង $I(1,0)$ ។

គេបាន ៖ $PI^2=(1-3)^2+(0-4)^2=4+16=20$ និង $AI^2=r^2=5$

តាមទ្រឹស្តីបទពីតាគ័រ , យើងបាន ៖

$$PA^2=IP^2-IA^2=20-5=15$$

$$PA=\sqrt{15}$$

ដូចនេះ ប្រវែង $AP=\sqrt{15}$ (ឯកតាប្រវែង) ត្រូវបានគណនា ។

218. គេមាន ABC គឺជាត្រីកោណមួយដែលមាន $AB=5, BC=4$ និង $\angle B=60^o$ ។

១. រកប្រវែងនៃអង្កត់ធ្នូ AC ។

២. គណនាប្រវែងកាំរង្វង់ចារឹកក្រៅត្រីកោណ ABC ។

៣. D គឺជាចំណុចមួយនៅលើធ្នូតូច AC ។ រកតម្លៃអតិបរមានៃផ្ទៃក្រឡារបស់ចតុកោណ $ABCD$ ។



ដំណោះស្រាយ

១. រកប្រវែងនៃអង្កត់ធ្នូ AC

តាមទ្រឹស្តីបទកូស៊ីនុស , គេបាន ៖ $AC^2 = AB^2 + BC^2 - 2(AB \cdot BC)\cos B$

ដោយ $AB = 5, BC = 4$ និង $\angle B = 60^o$ យើងបាន ៖

$$AC^2 = 5^2 + 4^2 - 2(5 \cdot 4)\cos 60^o$$

$$AC^2 = 41 - 20$$

$$AC = \sqrt{21}$$

ដូចនេះប្រវែងនៃអង្កត់ធ្នូ $AC = \sqrt{21}$ (ឯកតា) ត្រូវបានកំណត់ ។

២. គណនាប្រវែងកាំរង្វង់ចារឹកក្រៅត្រីកោណ ABC



គេបាន $\angle AOC = 2\angle B = 120^o \Rightarrow \angle AOH = \frac{1}{2}\angle AOC = 60^o$

ក្នុងត្រីកោណកែង AOH គេបាន ៖ $\sin \angle AOH = \frac{AH}{AO} \Rightarrow OA = \frac{AH}{\sin \angle AOH}$

$$OA = \frac{\frac{\sqrt{21}}{2}}{\sin 60^o} = \frac{\sqrt{21}}{2} \cdot \frac{2}{\sqrt{3}} = \sqrt{7} \text{ ឯកតាប្រវែង}$$

ដូចនេះរង្វង់ចារឹកក្រៅត្រីកោណ ABC មានរង្វាស់កាំ $\sqrt{7}$ ឯកតាប្រវែង ។

៣. រកតម្លៃអតិបរមានៃផ្ទៃក្រឡារបស់ចតុកោណ $ABCD$

ផ្ទៃក្រឡារបស់ចតុកោណ $ABCD$ គឺ ៖ $S_{ABCD} = S_{\Delta ABC} + S_{\Delta ACD}$

ផ្ទៃក្រឡាត្រីកោណ ABC គឺ ៖ $S_{\Delta ABC} = \frac{1}{2}(BA \cdot BC)\sin 60^o = 5\sqrt{3}$ ឯកតាផ្ទៃ (ថេរ)

ផ្ទៃក្រឡាត្រីកោណ ACD គឺ ៖ $S_{\Delta ACD} = \frac{1}{2}(DA \cdot DC)\sin D$ (អថេរ)

គេបាន , ផ្ទៃក្រឡារបស់ចតុកោណ $ABCD$ អតិបរមាកាលណាផ្ទៃក្រឡាត្រីកោណ ACD អតិបរមា ។

ដោយ $\angle D = 180^o - \angle B = 120^o$ (មុំឈមនៃចតុកោណចារឹកក្នុងរង្វង់)

នោះផ្ទៃក្រឡាត្រីកោណ ACD អតិបរមា កាលណាផលគុណ $DA \cdot DC$ អតិបរមា

យើងដឹងថា ចំនួនពិតវិជ្ជមាន a, b មានផលគុណអតិបរមា កាលណា $a = b$

នោះ ផលគុណ $DA \cdot DC$ អតិបរមា កាលណា $DA = DC$

មានន័យថា DAC ជាត្រីកោណសមបាតកំពូល D

នោះ $\angle DAC = \angle DCA = \frac{180^o - 120^o}{2} = 30^o$, គេបាន ៖

$$\frac{AD}{\sin 30^o} = \frac{AC}{\sin 120^o} \text{ (ទ្រឹស្តីបទស៊ីនុស)}$$

នាំឲ្យ $AD = CD = \frac{\sqrt{21} \cdot \frac{1}{2}}{\frac{\sqrt{3}}{2}} = \sqrt{7}$ ឯកតាប្រវែង

គេបាន $S_{\max \Delta ACD} = \frac{1}{2}\left(\sqrt{7}\right)^2 \sin 120^o = \frac{7}{2} \cdot \frac{\sqrt{3}}{2} = \frac{7\sqrt{3}}{4}$ ឯកតាផ្ទៃ

ដូចនេះផ្ទៃក្រឡាអតិបរមានៃចតុកោណ $ABCD$ គឺ $S_{\max ABCD} = 5\sqrt{3} + \frac{7\sqrt{3}}{4}$ ឯកតាផ្ទៃ ។

ណែនាំ ៖ ***ហេតុអ្វីបានជា $a \cdot b$ អតិបរមា កាលណា $a = b$?***

យើងមាន $(a+b)^2 = a^2 + b^2 + 2ab$

និង $(a-b)^2 = a^2 + b^2 - 2ab$ ***គេបាន ៖***

$$(a+b)^2 - (a-b)^2 = 4ab$$

$$ab = \frac{1}{4}\left((a+b)^2 - (a-b)^2\right) \le \frac{1}{4}(a+b)^2$$

សញ្ញាស្មើ(តម្លៃអតិបរមា)កើតមានកាលណា $a - b = 0 \Leftrightarrow a = b$ ***។***

219. ដោះស្រាយសមីការ $3x^3 - 10x^2 + 10x - 4 = 0$ ។

<u>ដំណោះស្រាយ</u>

ដោះស្រាយសមីការ

យើងមានសមីការ $3x^3 - 10x^2 + 10x - 4 = 0$ គេបាន ៖

$$\left(3x^3 - 6x^2\right) - \left(4x^2 + 8x\right) + (2x - 4) = 0$$

$$3x^2(x-2) - 4x(x-2) + 2(x-2) = 0$$

$$(x-2)\left(3x^2 - 4x + 2\right) = 0$$

បើ $x - 2 = 0$ នោះ $x_1 = 2$

បើ $3x^2 - 4x + 2 = 0$ នោះ $x_{2,3} = \frac{-(-2) \pm \sqrt{(-2)^2 - 6}}{3} = \frac{2 \pm i\sqrt{2}}{3}$

ដូចនេះ សមីការមានចម្លើយ $x_1 = 2, x_2 = \frac{2}{3} + i\frac{\sqrt{2}}{3}$ និង $x_3 = \frac{2}{3} - i\frac{\sqrt{2}}{3}$ ។

220. គេមាន α និង β ជាឫសរបស់សមីការ $2x^2-5x+1=0$ ហើយ $\frac{1}{\alpha}$ និង $\frac{1}{\beta}$ ជាឫសរបស់សមីការ $x^2+ax+b=0$ ។ រកតម្លៃនៃចំនួនថេរ a និង b ។

ដំណោះស្រាយ

រកតម្លៃនៃចំនួនថេរ a និង b

យើងមាន α និង β ជាឫសរបស់សមីការ $2x^2-5x+1=0$, តាមទ្រឹស្តីបទវ្យែត គេបាន៖

$$\alpha+\beta=\frac{5}{2}$$

$$\alpha\beta=\frac{1}{2}$$

ហើយ $\frac{1}{\alpha}$ និង $\frac{1}{\beta}$ ជាឫសរបស់សមីការ $x^2+ax+b=0$, គេបាន ៖

$$\frac{1}{\alpha}+\frac{1}{\beta}=-a$$

$$\frac{1}{\alpha}\cdot\frac{1}{\beta}=b$$

យើងបាន ៖

$$-a=\frac{1}{\alpha}+\frac{1}{\beta}=\frac{\alpha+\beta}{\alpha\beta}=\frac{\frac{5}{2}}{\frac{1}{2}}=5\Rightarrow a=-5$$

$$b=\frac{1}{\alpha\beta}=\frac{1}{\frac{1}{2}}=2$$

ដូចនេះ $a=-5$ និង $b=2$ ជាចំនួនដែល ត្រូវបានកំណត់ ។

221. តាង $\alpha=2,\beta=\sqrt{3}+i$ និង $\gamma=1+i$, $(i^2=-1)$ ។ រកតម្លៃដាច់ខាត r (ម៉ូឌុល) និងអាគុយម៉ង់ θ នៃ $\frac{\alpha+\beta}{\gamma}$, $(-\pi<\theta\leq\pi)$ ។

ដំណោះស្រាយ

រកតម្លៃដាច់ខាត r (ម៉ូឌុល) និងអាគុយម៉ង់ θ នៃ $\frac{\alpha+\beta}{\gamma}$, $(-\pi<\theta\leq\pi)$

យើងមាន $\alpha=2,\beta=\sqrt{3}+i$ និង $\gamma=1+i$ គេបាន ៖

$$\frac{\alpha+\beta}{\gamma}=\frac{2+\sqrt{3}+i}{1+i}=\frac{2\left(1+\frac{\sqrt{3}}{2}+\frac{1}{2}i\right)}{\sqrt{2}\left(\frac{1}{\sqrt{2}}+\frac{1}{\sqrt{2}}i\right)}=\frac{2\left(1+\cos\frac{\pi}{6}+i\sin\frac{\pi}{6}\right)}{\sqrt{2}\left(\cos\frac{\pi}{4}+i\sin\frac{\pi}{4}\right)}$$

$$=\frac{2\left(2\cos^2\frac{\pi}{12}+2i\sin\frac{\pi}{12}\cos\frac{\pi}{12}\right)}{\sqrt{2}\left(\cos\frac{\pi}{4}+i\sin\frac{\pi}{4}\right)}$$

$$=\frac{4\cos\frac{\pi}{12}\left(\cos\frac{\pi}{12}+i\sin\frac{\pi}{12}\right)}{\sqrt{2}\left(\cos\frac{\pi}{4}+i\sin\frac{\pi}{4}\right)}$$

$$=2\sqrt{2}\cos\frac{\pi}{12}\left(\cos\left(\frac{\pi}{12}-\frac{\pi}{4}\right)+i\sin\left(\frac{\pi}{12}-\frac{\pi}{4}\right)\right)$$

$$=\left(2\sqrt{2}\cos\frac{\pi}{12}\right)\left(\cos\left(-\frac{\pi}{6}\right)+i\sin\left(-\frac{\pi}{6}\right)\right)$$

ដូចនេះ , គេបាន តម្លៃដាច់ខាតនៃ $\frac{\alpha+\beta}{\gamma}$ គឺ ៖ $r=2\sqrt{2}\cos\frac{\pi}{12}=1+\sqrt{3}$

និងអាគុយម៉ង់ ៖ $\theta=-\frac{\pi}{6}$ (ព្រោះ $-\pi<\theta\le\pi$) ។

222. សន្មតថា $\lim\limits_{x\to\infty}\left(1+\frac{1}{kx}\right)^x=\sqrt{e}$ ។ រកតម្លៃនៃចំនួនថេរ k ។

<u>ដំណោះស្រាយ</u>

រកតម្លៃនៃចំនួនថេរ k

តាមរូបមន្ត , $\lim\limits_{u\to\infty}\left(1+\frac{1}{u}\right)^u=e$

គេបាន ៖ $\lim\limits_{x\to\infty}\left(1+\frac{1}{kx}\right)^x=\lim\limits_{kx\to\infty}\left(\left(1+\frac{1}{kx}\right)^{kx}\right)^{\frac{1}{k}}=e^{\frac{1}{k}}$

តែតាមបំរាប់ , $\lim\limits_{x\to\infty}\left(1+\frac{1}{kx}\right)^x=\sqrt{e}=e^{\frac{1}{2}}$ នាំឲ្យគេបាន ៖ $e^{\frac{1}{k}}=e^{\frac{1}{2}}\Rightarrow k=2$

ដូចនេះ $k=2$ ត្រូវបានកំណត់ ។

223. សន្មតថា α និង 3α គឺជាចម្លើយនៃសមីការត្រីជាដឺក្រេទី២ $3x^2+8x+k=0$ ដែល k គឺជាចំនួនពិត ថេរ ។ រកតម្លៃនៃ k ។

<u>ដំណោះស្រាយ</u>

រកតម្លៃនៃ k

យើងមាន α និង 3α ជាចម្លើយនៃសមីការ $3x^2+8x+k=0$ គេបាន ៖

$$\begin{cases}\alpha+3\alpha=-\dfrac{8}{3}\\ \alpha\cdot 3\alpha=\dfrac{k}{3}\end{cases}\Leftrightarrow\begin{cases}\alpha=-\dfrac{2}{3}\\ k=9\alpha^2\end{cases}\Rightarrow k=9\left(-\dfrac{2}{3}\right)^2=4$$

ដូចនេះចំនួនពិត បើនោះគឺ $k=4$ ត្រូវបានកំណត់ ។

224. គេមាន a គឺជាផ្នែកគត់ នៃ $\dfrac{1}{2-\sqrt{3}}$ និង b គឺជាផ្នែកទសភាគ ($0<b<1$) ។

ចូរគណនាតម្លៃនៃ $a-b+\dfrac{2}{b}$ ។

ដំណោះស្រាយ

គណនាតម្លៃនៃ $a-b+\dfrac{2}{b}$

យើងមាន a ជាផ្នែកគត់ និង b ជាផ្នែកទសភាគ ($0<b<1$)នៃ $\dfrac{1}{2-\sqrt{3}}$

គេបាន ៖ $\dfrac{1}{2-\sqrt{3}}=\dfrac{2+\sqrt{3}}{2^2-\left(\sqrt{3}\right)^2}=2+\sqrt{3}=3+\left(\sqrt{3}-1\right)$

នាំឲ្យគេបាន $a=3,b=\sqrt{3}-1$ ព្រោះ $0<b<1$

យើងបាន ៖ $a-b+\dfrac{2}{b}=3-\left(\sqrt{3}-1\right)+\dfrac{2}{\sqrt{3}-1}=2-\sqrt{3}+\dfrac{2\left(\sqrt{3}+1\right)}{\left(\sqrt{3}\right)^2-1}$

$$a-b+\frac{2}{b}=2-\sqrt{3}+\left(\sqrt{3}+1\right)=3$$

ដូចនេះ $a-b+\dfrac{2}{b}=3$ ត្រូវបានគណនា ។

225. សន្មតថា $\log_{10}A=a$ និង $\log_{10}B=b$ ចំពោះគ្រប់ចំនួនពិតវិជ្ជមាន A,B ខុសពី 1 ។

ឧបមាថា $a+b=0$ ។ រកតម្លៃនៃ $A^{\frac{1}{b}}B^{\frac{1}{a}}$ ។

ដំណោះស្រាយ

រកតម្លៃនៃ $A^{\frac{1}{b}}B^{\frac{1}{a}}$

ចំពោះគ្រប់ចំនួនពិតវិជ្ជមាន A,B ខុសពី 1 យើងមាន ៖

$\log_{10}A=a$ និង $\log_{10}B=b$ គេបាន ៖

$$\log_{10}\left(A^{\frac{1}{b}}B^{\frac{1}{a}}\right)=\frac{1}{b}\log_{10}A+\frac{1}{a}\log_{10}B$$

$$=\frac{1}{b}\cdot a+\frac{1}{a}\cdot b=\frac{a}{b}+\frac{b}{a}$$

នាំឲ្យ $A^{\frac{1}{b}}B^{\frac{1}{a}}=10^{\left(\frac{a}{b}+\frac{b}{a}\right)}$ តែ $a+b=0\Rightarrow\frac{a}{b}=-1$ និង $\frac{b}{a}=-1$

នាំឲ្យ $A^{\frac{1}{b}}B^{\frac{1}{a}}=10^{(-1-1)}=\frac{1}{100}$

ដូចនេះ $A^{\frac{1}{b}}B^{\frac{1}{a}}=\frac{1}{100}$ ត្រូវបានគណនា ។

226. បង្ហាញថា ចំពោះចំនួនគត់វិជ្ជមាន n នីមួយៗ , នោះមានចំនួនគត់វិជ្ជមាន m មួយដែលផ្ទៀងផ្ទាត់ $\left(1+\sqrt{2}\right)^n=\sqrt{m}+\sqrt{m+1}$ ។

<u>ដំណោះស្រាយ</u>

បង្ហាញថា មានចំនួនគត់វិជ្ជមាន m មួយដែលផ្ទៀងផ្ទាត់ $\left(1+\sqrt{2}\right)^n=\sqrt{m}+\sqrt{m+1}$

ដោយអនុវត្តន៍ទ្រឹស្តីបទទ្វេធា លើទ្វេធា $\left(1+\sqrt{2}\right)^n$ យើងឃើញថាមានចំនួនគត់វិជ្ជមាន a និង b ដែល $\left(1+\sqrt{2}\right)^n=a+\sqrt{2}b$ និង $\left(1-\sqrt{2}\right)^n=a-\sqrt{2}b$

គុណរវាងគ្នានៃអង្គទាំងសងខាងរបស់សមភាព , យើងបាន ៖

$$\left(a+\sqrt{2}b\right)\left(a-\sqrt{2}b\right)=\left(\left(1+\sqrt{2}\right)\left(1-\sqrt{2}\right)\right)^n$$

$$a^2-2b^2=\left(-1\right)^n$$

$$a^2-2b^2=\pm1$$

យើងកំណត់យក $m=\min\left(a^2,2b^2\right)$ យើងបាន ,

$$\sqrt{m}+\sqrt{m+1}=\sqrt{a^2}+\sqrt{2b^2}=a+\sqrt{2}b=\left(1+\sqrt{2}\right)^n$$

ដូចនេះ បំណោទត្រូវបានស្រាយបញ្ជាក់ ។

227. តាង $x,y,z\ge0$ ហើយផ្ទៀងផ្ទាត់ $x+y+z=3$ ។ បង្ហាញថា ៖

$$\frac{x^3}{y^3+8}+\frac{y^3}{z^3+8}+\frac{z^3}{x^3+8}\ge\frac{1}{9}+\frac{2}{27}\cdot\left(xy+yz+zx\right)$$ ។

តើសញ្ញាសមភាពកើតមាននៅពេលណា ?

<u>ដំណោះស្រាយ</u>

បង្ហាញថា $\frac{x^3}{y^3+8}+\frac{y^3}{z^3+8}+\frac{z^3}{x^3+8}\ge\frac{1}{9}+\frac{2}{27}\cdot\left(xy+yz+zx\right)$

ចំពោះ $x,y,z\ge0$, តាមវិសមភាពមធ្យមនព្វន្ត - មធ្យមធរណីមាត្រ , គេបាន ៖

$$\frac{x^3}{y^3+8}+\frac{y+2}{27}+\frac{y^2-2y+4}{27}\ge3\cdot\sqrt[3]{\frac{x^3}{27^2}}=\frac{x}{3}$$

ស្រដៀងគ្នានេះដែរ , គេក៏បាន ៖ $\frac{y^3}{z^3+8}+\frac{z+2}{27}+\frac{z^2-2z+4}{27}\ge\frac{y}{3}$

និង $\frac{z^3}{x^3+8}+\frac{x+2}{27}+\frac{x^2-2x+4}{27}\geq\frac{z}{3}$

ដោយ $x+y+z=3$, បូកអង្គ និងអង្គនៃវិសមភាពទាំង ៣ ខាងលើ គេបាន ៖

$$\frac{x^3}{y^3+8}+\frac{y+2}{27}+\frac{y^2-2y+4}{27}+\frac{y^3}{z^3+8}+\frac{z+2}{27}+\frac{z^2-2z+4}{27}+\frac{z^3}{x^3+8}+\frac{x+2}{27}$$
$$+\frac{x^2-2x+4}{27}\geq\frac{x}{3}+\frac{y}{3}+\frac{z}{3}$$

$$\frac{x^3}{y^3+8}+\frac{y^3}{z^3+8}+\frac{z^3}{x^3+8}\geq\frac{x+y+z}{3}+\frac{x+y+z}{27}-\frac{6}{9}-\frac{x^2+y^2+z^2}{27}$$
$$=\frac{4}{9}-\frac{(x+y+z)^2-2xy-2yz-2zx}{27}$$
$$=\frac{1}{9}+\frac{2}{27}\cdot(xy+yz+zx)$$

សញ្ញាសមភាពកើតមានកាលណា ៖

$$\frac{y+2}{27}=\frac{y^2-2y+4}{27}\Rightarrow y^2-3y+2=0\Rightarrow y=1, y=2$$

ស្រដៀងគ្នាដែរ , គេបាន ៖ $x=1, x=2$ និង $z=1, z=2$

តែតាមលក្ខខណ្ឌ $x+y+z=3$ នោះនាំឲ្យ $x=y=z=1$

ដូចនេះ វិសមភាព $\frac{x^3}{y^3+8}+\frac{y^3}{z^3+8}+\frac{z^3}{x^3+8}\geq\frac{1}{9}+\frac{2}{27}\cdot(xy+yz+zx)$ ត្រូវបានស្រាយបញ្ជាក់ ហើយសញ្ញាស្មើកើតមានកាលណា $x=y=z=1$ ។

228. យើងមាន $ABCD$ គឺជាចតុកោណប៉ោងមួយ តាង $\alpha=\angle DAB, \beta=\angle ADB, \gamma=\angle ACB$ $\delta=\angle DBC$ និង $\varepsilon=\angle DBA$ ។ សន្មតថា $\alpha<\frac{\pi}{2}, \beta+\gamma=\frac{\pi}{2}$ និង $\delta+2\varepsilon=\pi$ ។

បង្ហាញថា $(DB+BC)^2=AD^2+AC^2$ ។



<u>ដំណោះស្រាយ</u>

បង្ហាញថា $(DB+BC)^2=AD^2+AC^2$

តាង D' ជាចំណុចឆ្លុះនៃ D ធៀបនឹងបន្ទាត់ AB ។

យើងបាន ៖ $\angle D'BA=\angle DBA=\varepsilon$

នោះ $\angle D'BC=\angle D'BA+\angle ABD+\angle DBC=2\varepsilon+\delta=\pi$

ដូច្នេះ D', B និង C ជាបីចំណុចបិតនៅលើបន្ទាត់តែមួយ

ម្យ៉ាងទៀត , $\angle AD'C+\angle ACD'=\angle ADB+\angle ACB=\beta+\gamma=\frac{\pi}{2}$

ដូច្នេះ $\angle D'AC=\frac{\pi}{2}$ នោះ $D'AC$ ជាត្រីកោណកែង ។

តាមទ្រឹស្តីបទពីតាគ័រ , គេបាន ៖

$$D'C^2=D'A^2+AC^2$$

នាំឲ្យគេបាន ៖

$$(DB+DC)^2=(D'B+BC)^2=D'C^2=D'A^2+AC^2=AD^2+AC^2$$

ដូចនេះសមភាព $(DB+BC)^2=AD^2+AC^2$ ត្រូវបានស្រាយបញ្ជាក់ ។

229. រកពហុធាដឺក្រេទី៥ $p(x)$ ដែលផ្ទៀងផ្ទាត់ $p(x)+1$ ចែកដាច់នឹង $(x-1)^3$ និង $p(x)-1$ ចែកដាច់នឹង $(x+1)^3$ ។

ដំណោះស្រាយ

រកពហុធាដឺក្រេទី៥ $p(x)$

តាមបំរាប់ , $p(x)+1$ ចែកដាច់នឹង $(x-1)^3$ និង $p(x)-1$ ចែកដាច់នឹង $(x+1)^3$

គេបាន ៖ $p(-x)+1$ ចែកដាច់នឹង $(x+1)^3$ (ជំនួស x ដោយ $-x$ ក្នុងលក្ខខណ្ឌទី១)

ហើយ $p(-x)-1$ ចែកដាច់នឹង $(x-1)^3$ (ជំនួស x ដោយ $-x$ ក្នុងលក្ខខណ្ឌទី២)

ដោយ $p(x)+1$ និង $p(-x)-1$ ចែកដាច់នឹង $(x-1)^3$ ដូចគ្នា

នោះផលបូក $(p(x)+1)+(p(-x)-1)=p(x)+p(-x)$ ក៏ចែកដាច់នឹង $(x-1)^3$ ដែរ

ដូចគ្នាដែរ , ដោយ $p(x)-1$ និង $p(-x)+1$ ចែកដាច់នឹង $(x+1)^3$ ដូចគ្នា

នោះផលបូក $(p(x)-1)+(p(-x)+1)=p(x)+p(-x)$ ក៏ចែកដាច់នឹង $(x+1)^3$ ដែរ

គេបាន $p(x)+p(-x)$ ចែកដាច់នឹង $(x-1)^3$ ផង និង $(x+1)^3$ ផង

តែដោយកន្សោម $(x-1)^3$ និង $(x+1)^3$ គ្មានកត្តារួម ហើយផលគុណ $(x-1)^3\cdot(x+1)^3$ ជាពហុធាដឺក្រេទី ៦ ហើយ $p(x)+p(-x)$ ជាពហុធាដឺក្រេយ៉ាងច្រើនត្រឹមទី៥

នាំឲ្យ $p(x)+p(-x)=0 \Leftrightarrow p(-x)=-p(x)$

នេះមានន័យថា , $p(x)$ ជាអនុគមន៍ពហុធាសេស

គេបាន , មេគុណនៃតួដែលមានដឺក្រេគូក្នុងពហុធា $p(x)$ ត្រូវតែស្មើសូន្យ

តាមសម្រាយខាងលើ , $p(x)-1$ ចែកដាច់នឹង $(x+1)^3$

គេបាន $p(x)-1=(x+1)^3(Ax^2+Bx+C)$ (ជាពហុធាដឺក្រេទី៥)

នោះ ៖

$$p(x)-1=(x+1)^3(Ax^2+Bx+C)$$

$$p(x)=(x^3+3x^2+3x+1)(Ax^2+Bx+C)+1$$

$$p(x)=Ax^5+(B+3A)x^4+(C+3B+3A)x^3+(3C+3B+A)x^2+(3C+B)x+(C+1)$$

ដោយ ឲ្យមេគុណនៃតួដែលមានដឺក្រេគូស្មើសូន្យ , គេបាន ៖

$$\begin{cases} B+3A=0 \\ 3C+3B+A=0 \\ C+1=0 \end{cases} \Leftrightarrow \begin{cases} A=-\dfrac{3}{8} \\ B=\dfrac{9}{8} \\ C=-1 \end{cases}$$

គេបាន $p(x)=-\frac{3}{8}x^5+\left(-1+3\left(\frac{9}{8}\right)+3\left(-\frac{3}{8}\right)\right)x^3+\left(3(-1)+\frac{9}{8}\right)x$

ដូចនេះពហុធានោះគឺ $p(x)=-\frac{3}{8}x^5+\frac{5}{4}x^3-\frac{15}{8}x$ ត្រូវបានកំណត់ ។

230. ពហុធា $P(x)$ មានដឺក្រេទី n ដែលផ្ទៀងផ្ទាត់លក្ខខណ្ឌ $P(k)=2^k$ ចំពោះ $k=0,1,2,\ldots,n$ ។ រកតម្លៃនៃ $P(n+1)$ ។

<u>ដំណោះស្រាយ</u>

រកតម្លៃនៃ $P(n+1)$

ចំពោះ $0\le r\le n$, ពហុធា $\binom{x}{r}=\frac{x(x-1)\cdots(x-r+1)}{r!}$ គឺជាពហុធាដឺក្រេ r ។

អញ្ចឹង ពហុធាដឺក្រេ n គឺ $Q(x)=\binom{x}{0}+\binom{x}{1}+\cdots+\binom{x}{n}$

ដោយប្រើទ្រឹស្តីបទទ្វេធា $Q(k)=(1+1)^k=2^k$ ចំពោះ $k=0,1,2,\ldots,n$

ដូច្នេះ $P(x)=Q(x)$ ចំពោះគ្រប់តម្លៃ x ។

គេបាន , $P(n+1)=Q(n+1)=\binom{n+1}{0}+\binom{n+1}{1}+\cdots+\binom{n+1}{n}=2^{n+1}-1$

ដូចនេះ $P(n+1)=2^{n+1}-1$ ត្រូវបានគណនា ។

231. សន្មតថា $\frac{3}{2}\le x\le 5$ ។ បង្ហាញថា $2\sqrt{x+1}+\sqrt{2x-3}+\sqrt{15-3x}<2\sqrt{19}$ ។

<u>ដំណោះស្រាយ</u>

បង្ហាញថា $2\sqrt{x+1}+\sqrt{2x-3}+\sqrt{15-3x}<2\sqrt{19}$

គ្រប់ $\frac{3}{2}\le x\le 5$ យើងអនុវត្តន៍តាមវិសមភាព កូស៊ី , គេបាន ៖

$$\begin{aligned}2\sqrt{x+1}+\sqrt{2x-3}+\sqrt{15-3x}&=\sqrt{x+1}+\sqrt{x+1}+\sqrt{2x-3}+\sqrt{15-3x}\\&\le\sqrt{\left((x+1)+(x+1)+(2x-3)+(15-3x)\right)\left(1^2+1^2+1^2+1^2\right)}\\&=2\sqrt{x+14}\le 2\sqrt{5+14}=2\sqrt{19}\end{aligned}$$

សញ្ញាសមភាពកើតមានកាលណា $\sqrt{x+1}=\sqrt{2x-3}=\sqrt{15-3x}$ និង $x=5$

តែកាលណា $x=5$ នោះ $\sqrt{x+1}\ne\sqrt{2x-3}\ne\sqrt{15-3x}$ (សញ្ញាសមភាពមិនអាចកើតមាន)

ដូចនេះវិសមភាព $2\sqrt{x+1}+\sqrt{2x-3}+\sqrt{15-3x}<2\sqrt{19}$ ត្រូវបានស្រាយបញ្ជាក់ ។

232. តាង θ ជាមុំស្រួចមួយ ដែលផ្ទៀងផ្ទាត់សមីការអញ្ញាត x , $x^2+4x\cos\theta+\cot\theta=0$ មានឫសឌុប ។ ចូររកតម្លៃនៃ θ ។

ដំណោះស្រាយ

រកតម្លៃនៃ θ

យើងមាន θ ជាមុំស្រួច ($0<\theta<\frac{\pi}{2}$) និង សមីការ $x^2+4x\cos\theta+\cot\theta=0$ មានឫសឌុប

គេបាន , $\Delta'=(2\cos\theta)^2-\cot\theta=4\cos^2\theta-\cot\theta=0$

$$\Leftrightarrow \cos\theta\left(4\cos\theta-\frac{1}{\sin\theta}\right)=0$$

ដោយ $\cos\theta\neq 0$ និង $\sin\theta\neq 0$ គេបាន ៖

$$4\cos\theta\sin\theta-1=0$$

$$2\sin 2\theta=1$$

$$\sin 2\theta=\frac{1}{2}$$

$$\sin 2\theta=\sin\frac{\pi}{6}$$

នាំឲ្យ $2\theta=\frac{\pi}{6},2\theta=\pi-\frac{\pi}{6}$

សមមូល $\theta=\frac{\pi}{12},\theta=\frac{5\pi}{12}$

ដូចនេះតម្លៃនៃ θ គឺ $\frac{\pi}{12}$ និង $\frac{5\pi}{12}$ ត្រូវបានកំណត់ ។

233. រកគ្រប់ចំនួនគត់ x ដែល $(4-x)^{4-x}+(5-x)^{5-x}+10=4^x+5^x$ ។

ដំណោះស្រាយ

រកគ្រប់ចំនួនគត់ x

យើងមានសមីការ $(4-x)^{4-x}+(5-x)^{5-x}+10=4^x+5^x$

បើ $x<0$ នោះអង្គខាងឆ្វេងនៃសមីការជាចំនួនគត់ប៉ុន្តែអង្គខាងស្តាំវិញ $0<\frac{1}{4^x}+\frac{1}{5^x}<1$

បើ $x>5$ នោះអង្គខាងឆ្វេងនៃសមីការ តូចជាង $\frac{1}{4}$ ខណៈដែលអង្គខាងស្តាំជាចំនួនគត់វិជ្ជមាន ។

ដូច្នេះ , ចម្លើយរបស់សមីការដែលអាចមានគឺជាចំនួនគត់នៅចន្លោះ ពី 0 ដល់ 5

ឲ្យ $x=1$ គេបាន , $(4-1)^{4-1}+(5-1)^{5-1}+10=4^1+5^1$

$$3^3+4^4+10=4+5$$

$$27+256+10=9$$

$219=9$ មិនពិត

ឲ្យ $x=2$ គេបាន , $(4-2)^{4-2}+(5-2)^{5-2}+10=4^2+5^2$

$$2^2+3^3+10=16+25$$

$$4+27+10=41$$

$41=41$ ពិត

ឲ្យ $x=3$ គេបាន , $(4-3)^{4-3}+(5-3)^{5-3}+10=4^3+5^3$

$$1^1+2^2+10=64+125$$

$$1+4+10=189$$

$$15=189$$ មិនពិត

ឲ្យ $x=4$ គេបាន , $(4-4)^{4-4}+(5-4)^{5-4}+10=4^4+5^4$

$0^0+1^1+10=256+625$ មិនអាចគណនា 0^0

ដូចនេះសរុបមកចំនួនគត់ដែល ត្រូវរកគឺ $x=2$ ។

234. គេមាន O ជាចំណុចមួយនៅខាងក្នុងត្រីកោណ ABC ដែល $\overrightarrow{OA}+2\overrightarrow{OB}+3\overrightarrow{OC}=\vec{0}$ ។ ចូររកផលធៀបនៃក្រឡាផ្ទៃរបស់ត្រីកោណ ABC ជាមួយក្រឡាផ្ទៃរបស់ត្រីកោណ AOC ។

<u>ដំណោះស្រាយ</u>

រកផលធៀបនៃក្រឡាផ្ទៃរបស់ត្រីកោណ ABC ជាមួយក្រឡាផ្ទៃរបស់ត្រីកោណ AOC



ដូចបង្ហាញក្នុងរូប , យក D និង E ជាចំណុចកណ្តាលនៃជ្រុង AC និង BC រៀងគ្នា ។ នោះយើងបាន ៖

$$\overrightarrow{OA}+\overrightarrow{OC}=2\overrightarrow{OD} \qquad (1)$$

និង $2\left(\overrightarrow{OB}+\overrightarrow{OC}\right)=4\overrightarrow{OE} \qquad (2)$

តាមសមីការ (1) និង (2) យើងបាន ៖

$$\overrightarrow{OA}+2\overrightarrow{OB}+3\overrightarrow{OC}=2\left(\overrightarrow{OD}+2\overrightarrow{OE}\right)=\vec{0}$$

នេះមានន័យថា $\overrightarrow{OD}$ និង $\overrightarrow{OE}$ កូលីនេអ៊ែរគ្នា ហើយ $\left|\overrightarrow{OD}\right|=2\left|\overrightarrow{OE}\right|$ ។

យើងសន្និដ្ឋានបានថា ៖

$$\frac{S_{\Delta AEC}}{S_{\Delta AOC}}=\frac{3}{2}$$ និង $$\frac{S_{\Delta ABC}}{S_{\Delta AOC}}=\frac{3\cdot 2}{2}=3$$

ដូចនេះផលធៀបនៃក្រឡាផ្ទៃរបស់ត្រីកោណ ABC ជាមួយក្រឡាផ្ទៃរបស់ត្រីកោណ AOC គឺស្មើនឹង 3 ។

235. ស្ត្រីម្នាក់ បានកើត និងរស់នៅក្នុងសតវត្សទី ២០ ។ ដោយដឹងថាការ៉េនៃអាយុរបស់គាត់ ស្មើនឹងឆ្នាំដែលគាត់រស់នៅ ។ ចូររកអាយុរបស់គាត់នៅឆ្នាំ ១៩៨៨ ។

ដំណោះស្រាយ

រកអាយុរបស់គាត់នៅឆ្នាំ ១៩៨៨

យើងដឹងថា , សតវត្សទី ២០ គឺស្ថិតនៅចន្លោះពីឆ្នាំ 1900 ដល់ឆ្នាំ 1999

សន្មតថា x ($x\in\mathbb{N}$)ជាអាយុរបស់គាត់ដែល x^2 ស្មើនឹងឆ្នាំដែលគាត់រស់នៅ

គេបាន ៖

$$(x-1)^2<x^2<(x+1)^2$$

ដោយ $43^2=1849<1900$

និង $45^2=2025>1999$

នាំឲ្យ $x=44$ ព្រោះ $x^2=44^2=1936\in[1900,1999]$

មានន័យថា នៅឆ្នាំ 1936 គាត់មានអាយុ 44 ឆ្នាំ

នោះនៅឆ្នាំ ១៩៨៨ គាត់មានអាយុ ៖ $44+(1988-1936)=96$ ឆ្នាំ

ដូចនេះនៅឆ្នាំ ១៩៨៨ ស្ត្រីម្នាក់នោះមានអាយុ ៩៦ ឆ្នាំ ។

236. ដោះស្រាយសមីការ ៖ $2\left(x^2-3x+2\right)=3\sqrt{x^3+8}$ ។

ដំណោះស្រាយ

ដោះស្រាយសមីការ

យើងមានសមីការ $2\left(x^2-3x+2\right)=3\sqrt{x^3+8}$ (១)

លក្ខខណ្ឌ , សមីការ(១)មានន័យកាលណា ៖

$$\begin{cases}x^3+8\ge 0\\ x^2-3x+2\ge 0\end{cases}\Leftrightarrow\begin{cases}x\ge -2\\ x\in(-\infty,1]\cup[2,+\infty)\end{cases}\Leftrightarrow -2\le x\le 1\vee x\ge 2 \qquad (២)$$

តាង $\begin{cases}u=\sqrt{x^2-2x+4}\\ v=\sqrt{x+2}\end{cases}\Rightarrow\begin{cases}u^2=x^2-2x+4\\ v^2=x+2\end{cases}$

នោះ $u^2-v^2=x^2-3x+2$ និង $uv=\sqrt{\left(x^2-2x+4\right)\left(x+2\right)}=x^3+8$

នាំឲ្យ(១)សមមូលនឹង ៖

$$2\left(u^2-v^2\right)=3uv$$

$$2u^2-3uv-2v^2=0$$

$$\left(u-\frac{3}{4}v\right)^2-\left(\frac{5}{4}v\right)^2=0$$

$$\left(u-\frac{3}{4}v-\frac{5}{4}v\right)\left(u-\frac{3}{4}v+\frac{5}{4}v\right)=0$$

$$(u-2v)\left(u+\frac{1}{2}v\right)=0$$

តែតាម(២) នាំឲ្យគេបាន $u+\frac{1}{2}v>0$

នាំឲ្យគេបាន $u-2v=0$ នោះ $u=2v$

$$\Leftrightarrow u^2=4v^2$$

$$\Leftrightarrow x^2-2x+4=4x+8$$

$$\Leftrightarrow x^2-6x-4=0$$

$$\Delta'=9+4=13$$

$$x_{1,2}=\frac{-(-3)\pm\sqrt{13}}{1}=3\pm\sqrt{13} \quad (៣)$$

តាម (២) និង (៣) នាំឲ្យគេបាន $x_{1,2}=3\pm\sqrt{13}$ ជាចម្លើយនៃសមីការ (១) ។

237. ដោះស្រាយសមីការ ៖ $\sin^2 x+\sin^2 2x+\sin^2 3x=\frac{3}{2}$ ។

<u>ដំណោះស្រាយ</u>

ដោះស្រាយសមីការ

យើងមានសមីការ $\sin^2 x+\sin^2 2x+\sin^2 3x=\frac{3}{2}$ (១)

ដោយប្រើប្រាស់រូបមន្ត ៖ $\cos 2a=1-2\sin^2 a\Rightarrow \sin^2 a=\frac{1-\cos 2a}{2}$

នោះសមីការ(១)ទៅជា ៖

$$\frac{1-\cos 2x}{2}+\frac{1-\cos 4x}{2}+\frac{1-\cos 6x}{2}=\frac{3}{2}$$

$$\cos 2x+\cos 4x+\cos 6x=0$$

$$2\cos 4x\cos 2x+\cos 4x=0$$

$$\cos 4x(2\cos 2x+1)=0$$

បើ $\cos 4x=0\Leftrightarrow 4x=\frac{\pi}{2}+k\pi\Rightarrow x=\frac{\pi}{8}+\frac{k\pi}{4}$, $k\in\mathbb{Z}$

បើ $2\cos 2x+1=0\Leftrightarrow \cos 2x=-\frac{1}{2}\Leftrightarrow 2x=\pm\frac{2\pi}{3}+2k'\pi\Rightarrow x=\pm\frac{\pi}{3}+k'\pi$, $k'\in\mathbb{Z}$

ដូចនេះសមីការ(១)មានចម្លើយ $x=\frac{\pi}{8}+\frac{k\pi}{4}$, $x=\pm\frac{\pi}{3}+k'\pi$ ដែល $k,k'\in\mathbb{Z}$ ។

238. គេឲ្យ A,B,C ជាមុំទាំងបីរបស់ត្រីកោណមួយ ។

១. បង្ហាញថា $\dfrac{\cot\frac{A}{2}\cdot\cot\frac{B}{2}\cdot\cot\frac{C}{2}}{\cot\frac{A}{2}+\cot\frac{B}{2}+\cot\frac{C}{2}}=1$ ។

២. សន្មតថា $\cos C\cdot(\sin A+\sin B)=\sin C\cdot\cos(A-B)$ ។ ចូរកំណត់ $\cos A+\cos B$ ។

<u>ដំណោះស្រាយ</u>

១. បង្ហាញថា $\dfrac{\cot\frac{A}{2}\cdot\cot\frac{B}{2}\cdot\cot\frac{C}{2}}{\cot\frac{A}{2}+\cot\frac{B}{2}+\cot\frac{C}{2}}=1$ (១)

ក្នុងត្រីកោណ ABC មួយ , គេមាន ៖

$$A+B+C=\pi$$

$$\frac{A+B}{2}=\frac{\pi}{2}-\frac{C}{2}$$

$$\tan\left(\frac{A+B}{2}\right)=\tan\left(\frac{\pi}{2}-\frac{C}{2}\right)=\cot\frac{C}{2}$$

$$\tan\left(\frac{A+B}{2}\right)=\frac{1}{\tan\frac{C}{2}}$$

$$\tan\frac{C}{2}\left(\frac{\tan\frac{A}{2}+\tan\frac{B}{2}}{1-\tan\frac{A}{2}\tan\frac{B}{2}}\right)=1$$

$$\tan\frac{C}{2}\cdot\left(\tan\frac{A}{2}+\tan\frac{B}{2}\right)=1-\tan\frac{A}{2}\tan\frac{B}{2}$$

$$\tan\frac{A}{2}\tan\frac{B}{2}+\tan\frac{B}{2}\tan\frac{C}{2}+\tan\frac{C}{2}\tan\frac{A}{2}=1$$

$$\frac{1}{\cot\frac{A}{2}\cot\frac{B}{2}}+\frac{1}{\cot\frac{B}{2}\cot\frac{C}{2}}+\frac{1}{\cot\frac{C}{2}\cot\frac{A}{2}}=1$$

$$\frac{\cot\frac{A}{2}+\cot\frac{B}{2}+\cot\frac{C}{2}}{\cot\frac{A}{2}\cdot\cot\frac{B}{2}\cdot\cot\frac{C}{2}}=1$$

$$\frac{\cot\frac{A}{2}\cdot\cot\frac{B}{2}\cdot\cot\frac{C}{2}}{\cot\frac{A}{2}+\cot\frac{B}{2}+\cot\frac{C}{2}}=1$$

ដូចនេះសមភាព(១)ត្រូវបានស្រាយបញ្ជាក់ ។

២. កំណត់ $\cos A+\cos B$

យើងមាន $\cos C\cdot(\sin A+\sin B)=\sin C\cdot\cos(A-B)$ គេបាន ៖

$$2\cos C\cdot\sin\left(\frac{A+B}{2}\right)\cdot\cos\left(\frac{A-B}{2}\right)=2\sin\frac{C}{2}\cdot\cos\frac{C}{2}\cdot\left(2\cos^2\left(\frac{A-B}{2}\right)-1\right)$$

$$\cos C\cdot\sin\left(\frac{A-B}{2}\right)=\sin\frac{C}{2}\left(2\cos^2\left(\frac{A-B}{2}\right)-1\right)$$

$$\left(1-2\sin^2\frac{C}{2}\right)\cdot\cos\left(\frac{A-B}{2}\right)=\sin\frac{C}{2}\cdot\left(2\cos^2\left(\frac{A-B}{2}\right)-1\right)$$

$$\cos\left(\frac{A-B}{2}\right)+\sin\frac{C}{2}=2\sin^2\frac{C}{2}\cdot\cos\left(\frac{A-B}{2}\right)+2\sin\frac{C}{2}\cdot\cos^2\left(\frac{A-B}{2}\right)$$

$$\cos\left(\frac{A-B}{2}\right)+\sin\frac{C}{2}=2\sin\frac{C}{2}\cdot\cos\left(\frac{A-B}{2}\right)\left(\sin\frac{C}{2}+\cos\left(\frac{A-B}{2}\right)\right)$$

ដោយ $\sin\frac{C}{2}+\cos\left(\frac{A-B}{2}\right)\neq 0$ នោះគេបាន ៖

$$2\sin\frac{C}{2}\cdot\cos\left(\frac{A-B}{2}\right)=1$$

$$2\cos\left(\frac{A+B}{2}\right)\cos\left(\frac{A-B}{2}\right)=1$$

$$\cos A+\cos B=1$$

ដូចនេះ $\cos A+\cos B=1$ ត្រូវបានកំណត់ ។

239. រកគ្រប់ពហុធា $f(x)$ ដែលមានមេគុណជាចំនួនពិត ហើយផ្ទៀងផ្ទាត់លក្ខខណ្ឌ ៖

$$f(x)\cdot f(x+1)=f\left(x^2+x+1\right)$$ ។

ដំណោះស្រាយ

រកគ្រប់ពហុធា $f(x)$

យើងមាន $f(x)\cdot f(x+1)=f\left(x^2+x+1\right)$ (១)

(i)បើ $f(x)$ ជាពហុធាថេរ , នោះយើងតាង $f(x)=k$ គេបាន ៖

$$f(x+1)=k\ ,\ f\left(x^2+x+1\right)=k$$

នោះ(១)ក្លាយទៅជា ៖

$$k^2=k$$

$$k(k-1)=0$$

$$k=0\ ,\ k=1$$

ដូច្នេះ $f(x)$ ត្រូវតែស្មើនឹង 0 ឬ 1 ។

(ii)សន្មតថា $f(x)$ មិនមែនជាពហុធាថេរ , ឧបមាថា x_0 គឺជាឫសចំនួនពិតមួយនៃ $f(x)$

នោះ $x_1=x_0^2+x_0+1$ ក៏គឺជាឫសមួយនៃ $f(x)$ ដែរ , ដូច្នេះ

$$f(x_1)=f\left(x_0^2+x_0+1\right)=f(x_0)\cdot f(x_0+1)=0$$

តាមវិចារកំណើនគណិតវិទ្យា , នោះ បើ x_n គឺជាឫសមួយនោះ $x_{n+1}=x_n^2+x_n+1$ ក៏ជាឫសមួយទៀតដែរ ។

ដូច្នេះ , គេបាន $x_{n+1}-x_n=x_n^2+1>0$ នោះស្វ៊ីត $x_0,x_1,x_2,...$ គឺជាស្វ៊ីតកើន និងមិនកំណត់ តែចំនួននៃឫសរបស់ពហុធា $f(x)$ ត្រូវតែជាចំនួនកំណត់ ,

នេះគឺមានន័យថា សមីការ $f(x)=0$ មិនមានឫស ។

ដូច្នេះ $f(x)$ ត្រូវតែជាពហុធាដែលមានដឺក្រេគូ ។

ដោយប្រៀបធៀបមេគុណនៅក្នុងសមីការ(១) ហើយធ្វើការវិភាគ , គេបានលទ្ធផលថា តួដែលមានដឺក្រេខ្ពស់ជាងគេនៃ $f(x)$ ត្រូវតែមានមេគុណស្មើនឹង 1 ដាច់ខាត ។

យក $f(x)=x^2+c$ (២)

នោះតាម(១) គេបាន ,

$$(x^2+c)\left((x+1)^2+c\right)=(x^2+x+1)^2+c$$

$$x^4+2x^3+(2c+1)x^2+2cx+c(c+1)=x^4+2x^3+3x^2+2x+1$$

ដោយធ្វើការផ្ទឹមមេគុណ នៃសមភាពខាងលើ គេទាញបានថា $c=1$

ដូច្នេះ ពហុធា $f(x)=x^2+1$ ផ្ទៀងផ្ទាត់លក្ខខណ្ឌដែលឲ្យ

យក $f(x)=x^4+cx^3+dx^2+ex+f$ (៣)

ជំនួស សមីការ (៣) ទៅក្នុងលក្ខខណ្ឌនៃសមីការ (១) រួចធ្វើការផ្ទឹមមេគុណ គេបាន ,

$$c=0,d=2,e=0,f=1$$

ដូច្នេះ ពហុធា $f(x)=x^4+2x^2+1=(x^2+1)^2$ ផ្ទៀងផ្ទាត់លក្ខខណ្ឌដែលឲ្យ

យើងអាចបង្ហាញថា $f(x)=(x^2+1)^n$ ដែល $n=1,2,3,...$ ផ្ទៀងផ្ទាត់លក្ខខណ្ឌដែលឲ្យ

យើងបាន ,

$$f(x)\cdot f(x+1)=(x^2+1)^n\left((x+1)^2+1\right)^n=\left(x^4+2x^3+4x^2+2x+3\right)^n$$

និង $f(x)\cdot f(x^2+x+1)=\left((x^2+x+1)^2+1\right)^n=\left(x^4+2x^3+4x^2+2x+3\right)^n$

យើងនឹងបង្ហាញថា , មានចម្លើយតែមួយបែបនេះគត់ ។

តាងពហុធា $g(x)$ ដែល $g(x)=f(x)-(x^2+1)^n$

បើ $g(x)=0$ នោះសម្រាយបញ្ជាក់នឹងត្រូវបានបញ្ចប់ ។

ឧបមាថា $g(x)\neq 0$ និងដឺក្រេនៃ $g(x)$ គឺ $s<2n$,

តាម (១) និង $f(x)=(x^2+1)^n+g(x)$, យើងបាន ៖

$$(x^2+1)^n g(x+1)+\left((x+1)^2+1\right)g(x)=g(x^2+x+1)-g(x)\cdot g(x+1) \quad (៤)$$

ដឺក្រេនៃ (៤) លើអង្គខាងឆ្វេងគឺ $2n+s$ និងនៅលើអង្គខាងស្តាំគឺតិចជាង ឬស្មើនឹង $2s$ នេះគឺមានលក្ខណៈខុសគ្នា ។

គេទាញបាន $g(x)=0$ និង $f(x)=(x^2+1)^n$ ។

ដូចនេះសរុបមកវិញ ពហុធាដែលត្រូវរកគឺ $0,1,(x^2+1)^n$ ដែល n ជាចំនួនគត់វិជ្ជមាន ។

240. អនុគមន៍ $f(x)$ ផ្ទៀងផ្ទាត់លក្ខខណ្ឌខាងក្រោម ៖
(i) បំពោះគ្រប់ចំនួនសនិទាន x , $f(x)$ គឺជាចំនួនពិត
(ii) $f(2013) \neq f(2012)$
(iii) $f(x+y) = f(x)f(y) - f(xy) + 1$ បំពោះគ្រប់ចំនួនសនិទាន x និង y
បង្ហាញថា $f\left(-\frac{2012}{2013}\right) = \frac{1}{2013}$ ។

<u>ដំណោះស្រាយ</u>

បង្ហាញថា $f\left(-\frac{2012}{2013}\right) = \frac{1}{2013}$

តាមលក្ខខណ្ឌ $f(x+y) = f(x)f(y) - f(xy) + 1$ (១)

យើងជំនួសលើកដំបូង $x = y = 0$ ទៅក្នុង(១) គេបាន ៖

$$f(0) = f(0)f(0) - f(0) + 1$$

$$\left(f(0) - 1\right)^2 = 0$$

នាំឲ្យ $f(0) = 1$ (២)

ជាបន្ទាប់ , ជំនួស $x = 1, y = -1$ ទៅក្នុង(១) គេបាន ៖

$$f(0) = f(1)f(-1) - f(-1) + 1$$

តាម(២) នាំឲ្យគេបាន $f(-1)\left(f(1) - 1\right) = 0$

ដូច្នេះ វាមានពីរករណីកើតឡើងជាចាំបាច់ គឺ $f(1) = 1$ ឬ $f(-1) = 0$

ករណីទី១ ៖ $f(1) = 1$, យើងជំនួស $y = 1$ ទៅក្នុង (១) គេបាន ៖

$$f(x+1) = f(x)f(1) - f(x) + 1$$

$$f(x+1) = f(x) - f(x) + 1$$

$f(x+1) = 1$ បំពោះគ្រប់តម្លៃនៃចំនួនសនិទាន x

ក៏ប៉ុន្តែ តាមលក្ខខណ្ឌដែលឲ្យ $f(2012) \neq f(2013)$ ដូច្នេះយើងត្រូវការលក្ខខណ្ឌតែមួយគត់ គឺ ៖

ករណីទី២ ៖ $f(-1) = 0$, ក្នុង(១) យើងយក $x = y = -1$ នោះ ៖

$$f(-2) = f(-1)f(-1) - f(1) + 1$$

នោះ $f(-2) = 1 - f(1)$ (៣)

បន្ទាប់មក យើងជំនួស $x = -2$ និង $y = 1$ ក្នុង (១) គេបាន ៖

$$f(-1) = f(-2)f(1) - f(-2) + 1$$

$$0 = f(-2)f(1) - f(-2) + 1$$

$0 = f(-2)f(1) - f(1)$ តាម(៣)

$$0 = \left(f(-2) - 1\right)f(1)$$

ជាថ្មីម្តងទៀត , វាមានពីរករណីដែលអាចកើតមានឡើង គឺ $f(1) = 0$ ឬ $f(-2) = -1$

ករណីទី១ ៖ $f(1)=0$, ជំនួស $y=1$ ទៅក្នុង(១) គេបាន ៖

$$f(x+1)=f(x)f(1)-f(x)+1=1-f(x)$$

នោះ $f(x+2)=f(x)$ (៤)

តាម(១) យើងយក $x=2, y=\frac{1}{2}$ គេបាន ៖

$$f\left(2+\frac{1}{2}\right)=f(2)f\left(\frac{1}{2}\right)-f\left(2\cdot\frac{1}{2}\right)+1=f\left(\frac{1}{2}\right)+1$$

ប៉ុន្តែ , តាម(៤) យើងមាន $f\left(\frac{1}{2}+2\right)=f\left(\frac{1}{2}\right)$ នេះវាមានភាពផ្ទុយគ្នាស្រឡះ

ដូច្នេះយើងនូវសល់តែមួយករណីប៉ុណ្ណោះដែលអាចទៅរួច គឺ ៖

ករណីទី២ ៖ $f(-2)=-1$, តាម(៣) គេបាន ៖

$f(-2)=1-f(1)$ នោះយើងទាញបាន $f(1)=2$

តាម(១) គេបាន ,

$$f(x+1)=f(x)f(1)-f(x)+1=2f(x)-f(x)+1$$

$$f(x+1)=f(x)+1 \quad (៥)$$

ដូច្នេះ $f(0)=1$ តាម(២) , នេះផ្ទៀងផ្ទាត់តាមវិចារកំណើន ថា $f(x)+1$ បើ x ជាចំនួនគត់ ។

ជាបន្ត , បើ n ជាចំនួនគត់វិជ្ជមានស្រេចនឹងចិត្ត នោះពី(១) ៖

$$f\left(1+\frac{1}{n}\right)=f(n)f\left(\frac{1}{n}\right)-f\left(n\cdot\frac{1}{n}\right)+1$$

គេទាញបាន $n+f\left(\frac{1}{n}\right)=(n+1)f\left(\frac{1}{n}\right)-1$

តាម(៥) និង $nf\left(\frac{1}{n}\right)=n+1$ មានន័យថា $f\left(\frac{1}{n}\right)=1+\frac{1}{n}$ ។

បើ k គឺជាចំនួនគត់មួយ នោះពី(១) ៖

$$f\left(k+\frac{1}{n}\right)=f(k)f\left(\frac{1}{n}\right)-f\left(\frac{k}{n}\right)+1$$

នេះមានន័យថា ,

$$\frac{1}{n}+k+1=(k+1)\left(1+\frac{1}{n}\right)-f\left(\frac{k}{n}\right)+1$$

និង $$f\left(\frac{k}{n}\right)=\frac{k}{n}+1$$

សរុបមកវិញ , ចំពោះគ្រប់ចំនួនសនិទាន x , យើងបាន $f(x)=x+1$

ដូច្នេះ $f\left(-\frac{2012}{2013}\right)=1-\frac{2012}{2013}=\frac{1}{2013}$

ដូចនេះ $f\left(-\frac{2012}{2013}\right)=\frac{1}{2013}$ ត្រូវបានបង្ហាញ ។

241. រកគ្រប់អនុគមន៍ f ដែល ៖

(i) យកតម្លៃជាចំនួនពិត

(ii) កំណត់បានគ្រប់ចំនួន $x \neq \frac{2}{3}$, និង

(iii) ផ្ទៀងផ្ទាត់លក្ខខណ្ឌ

$503x - f(x) = \frac{1}{2} f\left(\frac{2x}{3x-2}\right)$ ចំពោះគ្រប់តម្លៃនៃ x លើកលែង $\frac{2}{3}$ ។

<u>ដំណោះស្រាយ</u>

រកគ្រប់អនុគមន៍ f

យើងមាន $f : \mathbb{R} \setminus \left\{\frac{2}{3}\right\} \to \mathbb{R}$ ដែល $503x - f(x) = \frac{1}{2} f\left(\frac{2x}{3x-2}\right)$ (១)

តាង $u = \frac{2x}{3x-2}$, $x \neq \frac{2}{3}$

នោះ $x = \frac{2u}{3u-2}$, $u \neq \frac{2}{3}$

ជំនួស x ក្នុង(១)ដោយ u យើងបាន ៖

$$503u - f(u) = \frac{1}{2} f\left(\frac{2u}{3u-2}\right)$$

មានន័យថា $\frac{1006x}{3x-2} - f\left(\frac{2x}{3x-2}\right) = \frac{1}{2} f(x)$ (២)

ហើយសមីការ(១)អាចសរសេរជា $1006x - f\left(\frac{2x}{3x-2}\right) = 2f(x)$ (៣)

ដកអង្គ និងអង្គនៃ (៣) និង(២) , គេបាន ៖

$$1006x - \frac{1006x}{3x-2} = \frac{3}{2} f(x)$$

$$\frac{1006x(3x-2-1)}{3x-2} = \frac{3}{2} f(x)$$

$$\frac{2012x(x-1)}{3x-2} = f(x)$$

ដូចនេះអនុគមន៍ដែលត្រូវរកនោះគឺ $f(x) = \frac{2012x(x-1)}{3x-2}$ ដែល $x \neq \frac{2}{3}$ ។

242. ចំពោះអនុគមន៍ f ដែលកំណត់លើគ្រប់ចំនួនពិត និងផ្ទៀងផ្ទាត់លក្ខខណ្ឌ ៖

$f(xy) = x \cdot f(y) + f(x) \cdot y$ និង $f(x+y) = f\left(x^{2013}\right) + f\left(y^{2013}\right)$ ។

ចូរកំណត់តម្លៃនៃ $f\left(\sqrt{2556}\right)$ ។

ដំណោះស្រាយ

កំណត់តម្លៃនៃ $f\left(\sqrt{2556}\right)$

យើងមាន $f:\mathbb{R}\to\mathbb{R}$ ហើយ , $f(xy)=x\cdot f(y)+f(x)\cdot y$ (១)

និង $f(x+y)=f\left(x^{2013}\right)+f\left(y^{2013}\right)$ (២)

យក $x=y=0$ ជំនួសក្នុង(២) យើងនឹងបាន ៖

$$f(0)=2f(0)$$

នាំឲ្យ $f(0)=0$

ក្នុង(១) យក $x=y=1$ នោះ ,

$$f(1)=2f(1)$$

នាំឲ្យ $f(1)=0$

ក្នុង(២) យក $x=a$ និង $y=0$, នោះ $f(a)=f\left(a^{2013}\right)$ ចំពោះគ្រប់ចំនួនពិត a ។

គេក៏ទាញបានថា $f\left(x^{2013}\right)=f(x)$ និង $f\left(y^{2013}\right)=f(y)$

នោះគេទាញបាន (២) ៖ $f(x+y)=f(x)+f(y)$ (៣)

យក $y=1$ ជំនួសក្នុងសមីការ(៣) , គេបាន ៖

$$f(x+1)=f(x)+f(1)=f(x)+0=f(x)$$ ចំពោះគ្រប់ចំនួនពិត x

តែដោយ $f(0)=0$ នោះតាមវិចារកំណើនគណិតវិទ្យា , យើងអាចបង្ហាញបានថា $f(n)=0$ ចំពោះគ្រប់ n ជាចំនួនគត់មិនអវិជ្ជមាន ។

យើងនឹងប្រើលទ្ធផលនេះដើម្បីនឹងរក $f\left(\sqrt{2556}\right)$ ។

យក $x=y=\sqrt{2556}$ ជំនួសក្នុង(១) គេបាន ៖

$$f\left(\sqrt{2556}\cdot\sqrt{2556}\right)=\sqrt{2556}\cdot f\left(\sqrt{2556}\right)+f\left(\sqrt{2556}\right)\cdot\sqrt{2556}$$

$$f(2556)=2\sqrt{2556}\,f\left(\sqrt{2556}\right)$$

$$0=2\sqrt{2556}\,f\left(\sqrt{2556}\right)$$

$$f\left(\sqrt{2556}\right)=0$$

ដូចនេះ $f\left(\sqrt{2556}\right)=0$ ត្រូវបានគណនា ។

243. គេឲ្យចតុកោណប៉ោង $ABCD$ ។ សន្មត M,N គឺជាចំណុចកណ្ដាលនៃ AB,CD ។ បង្ហាញថា ៖

ក. $2\overrightarrow{MN}=\overrightarrow{AC}+\overrightarrow{BD}=\overrightarrow{AD}+\overrightarrow{BC}$ ។

ខ. $MN\le\max(AD,BC)$ ។

ដំណោះស្រាយ

ក. បង្ហាញថា $2\overrightarrow{MN}=\overrightarrow{AC}+\overrightarrow{BD}=\overrightarrow{AD}+\overrightarrow{BC}$



តាមទំនាក់ទំនងសាល , យើងបាន ៖

$$\overrightarrow{MN}=\overrightarrow{MA}+\overrightarrow{AC}+\overrightarrow{CN} \qquad (១)$$

$$\overrightarrow{MN}=\overrightarrow{MB}+\overrightarrow{BD}+\overrightarrow{DN} \qquad (២)$$

បូកអង្គ និងអង្គនៃ (១) និង (២) គេបាន ៖

$$2\overrightarrow{MN}=\left(\overrightarrow{MA}+\overrightarrow{MB}\right)+\overrightarrow{AC}+\overrightarrow{BD}+\left(\overrightarrow{CN}+\overrightarrow{DN}\right) \qquad (៣)$$

ដោយ M និង N ជាចំណុចកណ្តាលនៃ AB និង CD , គេបាន ៖

$$\overrightarrow{MA}+\overrightarrow{MB}=\vec{0} \text{ និង } \overrightarrow{MC}+\overrightarrow{MD}=\vec{0}$$

នោះ(៣) គេបាន ៖ $2\overrightarrow{MN}=\overrightarrow{AC}+\overrightarrow{BD}=\overrightarrow{AD}+\overrightarrow{DC}+\overrightarrow{BC}+\overrightarrow{CD}=\overrightarrow{AD}+\overrightarrow{BC}$

ដូចនេះ $2\overrightarrow{MN}=\overrightarrow{AC}+\overrightarrow{BD}=\overrightarrow{AD}+\overrightarrow{BC}$ ត្រូវបានបង្ហាញ ។

ខ. បង្ហាញថា $MN\le\max\left(AD,BC\right)$

តាង $m=\max\left(AD,BC\right)$, គេបាន ៖

$$\begin{aligned}2\left|\overrightarrow{MN}\right|&=\left|\overrightarrow{AD}+\overrightarrow{BC}\right|\\&\le\left|\overrightarrow{AD}\right|+\left|\overrightarrow{BC}\right|\\&=AD+BC\\2\left|\overrightarrow{MN}\right|&\le m+m=2m\end{aligned}$$

នាំឲ្យ $MN=\left|\overrightarrow{MN}\right|\le\max\left(AD,BC\right)$

ដូចនេះ $MN\le\max\left(AD,BC\right)$ ត្រូវបានបង្ហាញ ។

244. ដោះស្រាយប្រព័ន្ធវិសមីការ ៖ $\begin{cases}4^{x+y-1}+3\cdot4^{2y-1}\le2\\x+3y\ge2-\log_4 3\end{cases}$ ។

ដំណោះស្រាយ

ដោះស្រាយប្រព័ន្ធវិសមីការ ៖ $\begin{cases}4^{x+y-1}+3\cdot4^{2y-1}\le2\\x+3y\ge2-\log_4 3\end{cases}$

តាង $\begin{cases}a=4^{x+y-1}>0\\b=3\cdot4^{2y-1}>0\end{cases}$ នោះប្រព័ន្ធសមីការក្លាយទៅជា ,

$$\begin{cases} 0 < a+b \le 2 \\ ab = 3\cdot 4^{x+3y-2} \ge 3\cdot 4^{-\log_4 3} = 3\cdot\dfrac{1}{3} = 1 \end{cases}$$

$$\Rightarrow \begin{cases} 0 < a+b \le 2 \\ ab \ge 1 \end{cases}$$

ម្យ៉ាងទៀត , គេបាន ៖

$$(a-b)^2 = (a+b)^2 - 4ab \le 4-4 = 0$$

នាំឲ្យ $a-b=0 \Rightarrow a=b$

នោះគេបាន $a=b=1$

នាំឲ្យយើងបាន ,

$$\begin{cases} x+y-1=0 \\ 2y-1 = \log_4\dfrac{1}{3} \end{cases}$$

$$\begin{cases} x = \dfrac{1}{2}(1+\log_4 3) \\ y = \dfrac{1}{2}(1-\log_4 3) \end{cases}$$

ដូចនេះចម្លើយរបស់វិសមីការគឺ $x = \dfrac{1}{2}(1+\log_4 3)$ និង $y = \dfrac{1}{2}(1-\log_4 3)$ ។

245. ដោះស្រាយប្រព័ន្ធវិសមីការ ៖ $\begin{cases} \log_{\frac{1}{5}}\sqrt{5-x} < \log_{\frac{1}{5}}(3-x) \\ \left(x+\dfrac{1}{3}\right) \in \mathbb{N} \end{cases}$ ។

<u>ដំណោះស្រាយ</u>

ដោះស្រាយប្រព័ន្ធវិសមីការ ៖ $\begin{cases} \log_{\frac{1}{5}}\sqrt{5-x} < \log_{\frac{1}{5}}(3-x) & (1) \\ \left(x+\dfrac{1}{3}\right) \in \mathbb{N} & (2) \end{cases}$

តាម (1) គេបាន ៖

$$\sqrt{5-x} > 3-x > 0$$

$$\begin{cases} 5-x > (3-x)^2 \\ 3-x > 0 \end{cases}$$

$$\begin{cases} 5-x > 9-6x+x^2 \\ x < 3 \end{cases}$$

$$\begin{cases} x^2-5x+4 < 0 \\ x < 3 \end{cases}$$

$$\begin{cases} 1 < x < 4 \\ x < 3 \end{cases} \Rightarrow 1 < x < 3 \Leftrightarrow \dfrac{4}{3} < x+\dfrac{1}{3} < \dfrac{10}{3}$$

តែតាម (2) ៖ $x+\frac{1}{3}\in\mathbb{N}$ នាំឲ្យគេបាន $x+\frac{1}{3}\in\{2,3\}\Leftrightarrow x\in\left\{\frac{5}{3},\frac{8}{3}\right\}$

ដូចនេះប្រព័ន្ធវិសមីការមានចម្លើយ $x=\frac{5}{3}$ ឬ $x=\frac{8}{3}$ ។

246. ស្រាយបញ្ជាក់ថា ៖

ក. $2222^{5555}+5555^{2222}$ ចែកដាច់នឹង 7 ។

ខ. $2010^{2011}+2012^{2013}+2014^{2015}+3$ ចែកដាច់នឹង 7 ។

<u>ដំណោះស្រាយ</u>

ក. ស្រាយបញ្ជាក់ថា $2222^{5555}+5555^{2222}$ ចែកដាច់នឹង 7

យើងមាន ៖ $2222=7\times 317+3=7k+3$ ដែល $k=317$

$5555=7\times 793+4=7l+4$ ដែល $k=793$

គេបាន ,

$$\begin{aligned}2222^{5555}+5555^{2222}&=(7k+3)^{5555}+(7l+4)^{2222}\\&=7m+3^{5555}+7n+4^{2222}\end{aligned}$$

ដែល $m,n\in\mathbb{N}$

សមមូល ,

$$\begin{aligned}2222^{5555}+5555^{2222}&=7(m+n)+\left(3^5\right)^{1111}+\left(4^2\right)^{1111}\\&=7q+243^{1111}+16^{1111}\\&=7q+(243+16)r\\&=7q+7\cdot 37r\\&=7s\end{aligned}$$

ដូចនេះ $2222^{5555}+5555^{2222}$ ចែកដាច់នឹង 7 ត្រូវបានស្រាយបញ្ជាក់ ។

ខ. ស្រាយបញ្ជាក់ថា $2010^{2011}+2012^{2013}+2014^{2015}+3$ ចែកដាច់នឹង 7

យើងមាន ៖ $2010=7\cdot 287+1=7m+1$ ដែល $m=287$

$2012=7\cdot 287+3=7m+3$ ដែល $m=287$

$2014=7\cdot 288-2=7n-2$ ដែល $n=288$

គេបាន ,

$$\begin{aligned}2010^{2011}+2012^{2013}+2014^{2015}+2&=(7m+1)^{2011}+(7m+3)^{2013}+(7n-2)^{2015}+3\\&=7p+1+7q+3^{2013}+7r+2^{2015}+3\\&=7(p+q+r)+3^{2013}+2^{2015}+4\\&=7s+3^{2013}+2^{2015}+4\end{aligned}$$

យើងមាន ៖

$$
\begin{aligned}
3^{2013} &\equiv 3\left(3^2\right)^{1006} \pmod 7 \\
&\equiv 3\cdot 2^{1006} \pmod 7 \\
&\equiv 3\cdot 4^{503} \pmod 7 \\
&\equiv 3\cdot 4\cdot 4^{502} \pmod 7 \\
&\equiv 12\cdot 4^{502} \pmod 7 \\
&\equiv 5\cdot 16^{251} \pmod 7 \\
&\equiv 5\cdot 2^{251} \pmod 7 \\
&\equiv 10\cdot 2^{250} \pmod 7 \\
&\equiv 3\cdot 32^{50} \pmod 7 \\
&\equiv 3\cdot 4^{50} \pmod 7 \\
&\equiv 3\cdot 16^{25} \pmod 7 \\
&\equiv 3\cdot \left(2^5\right)^5 \pmod 7 \\
&\equiv 3\cdot 4^{5} \pmod 7 \\
&\equiv 3\cdot 32^{2} \pmod 7 \\
&\equiv 3\cdot 4^{2} \pmod 7 \\
&\equiv 3\cdot 2 \pmod 7 \\
&\equiv 6 \pmod 7
\end{aligned}
$$

ហើយ

$$
\begin{aligned}
2^{2015} &\equiv 4^{403} \pmod 7 \\
&\equiv 4\cdot \left(4^2\right)^{201} \pmod 7 \\
&\equiv 4\cdot 2^{201} \pmod 7 \\
&\equiv 8\cdot 2^{200} \pmod 7 \\
&\equiv 32^{40} \pmod 7 \\
&\equiv \left(4^2\right)^{20} \pmod 7 \\
&\equiv 2^{20} \pmod 7 \\
&\equiv 32^{4} \pmod 7 \\
&\equiv 4^{4} \pmod 7 \\
&\equiv 16^{2} \pmod 7 \\
&\equiv 2^{2} \pmod 7 \\
&\equiv 4 \pmod 7
\end{aligned}
$$

គេបាន ៖ $3^{2013}+2^{2015}+4\equiv 6\pmod 7+4\pmod 7+4\pmod 7\equiv (6+4+4)\pmod 7$

នាំឲ្យ $3^{2013}+2^{2015}+4\equiv 14\pmod 7\equiv 0\pmod 7$

ដូចនេះ $2010^{2011}+2012^{2013}+2014^{2015}+3$ ចែកដាច់នឹង 7 ត្រូវបានស្រាយបញ្ជាក់ ។

247. គេឲ្យចំនួនពិត m និង n ដែលផ្ទៀងផ្ទាត់ $11m+10n=9$ ។
ចូរគណនាតម្លៃអតិបរមានៃអនុគមន៍ពីរអថេរ $f(m,n)=(m+9)(n+6)(10m+9n)$ ។

ដំណោះស្រាយ

គណនាតម្លៃអតិបរមានៃអនុគមន៍ពីរអថេរ $f(m,n)=(m+9)(n+6)(10m+9n)$
យើងមាន $11m+10n=9$ ចំពោះគ្រប់ចំនួនពិត m និង n
តាមវិសមភាព មធ្យមនព្វន្ត-មធ្យមធរណីមាត្រ , គេបាន ៖

$$\frac{(m+9)+(n+6)+(10m+9n)}{3}\ge\sqrt[3]{(m+9)(n+6)(10m+9n)}$$

$$\frac{11m+10n+15}{3}\ge\sqrt[3]{(m+9)(n+6)(10m+9n)}$$

$$\frac{9+15}{3}\ge\sqrt[3]{f(m,n)}$$

$$f(m,n)\le 8^3$$

$$f(m,n)\le 512$$

គេមាន $\max f(m,n)=512$ កាលណា $m+9=n+6=10m+9n\Rightarrow m=-1,n=2$
ដូចនេះតម្លៃអតិបរមានៃអនុគមន៍ f គឺ 512 កាលណា $m=-1,n=2$ ។

248. បើ a,b,c,d ជាចំនួនពិតដែលផ្ទៀងផ្ទាត់ $a^2+b^2+c^2+d^2=2013^2$ ។
បង្ហាញថា $a^3+b^3+c^3+d^3\le 2013^3$ ។

ដំណោះស្រាយ

បង្ហាញថា $a^3+b^3+c^3+d^3\le 2013^3$
យើងមាន $a^2+b^2+c^2+d^2=2013^2$ ដែល a,b,c,d ជាចំនួនពិត
គេបាន , $a^2=2013^2-\left(b^2+c^2+d^2\right)\le 2013^2$
នោះយើងបាន $a\le 2013\Rightarrow a-2013\le 0$
នាំឲ្យគេបាន ,

$$a^2(a-2013)\le 0$$

$$a^3-2013a^2\le 0$$

$$a^3\le 2013a^2 \qquad (1)$$

ស្រដៀងគ្នានេះដែរ , គេបាន ៖

$$b^3\le 2013b^2 \qquad (2)$$

$$c^3\le 2013c^2 \qquad (3)$$

និង $$d^3\le 2013d^2 \qquad (4)$$

បូកអង្គ និងអង្គនៃវិសមភាព $(1),(2),(3)$ និង (4) គេបាន ៖

$a^3+b^3+c^3+d^3 \le 2013a^2+2013b^2+2013c^2+2013d^2$

$a^3+b^3+c^3+d^3 \le 2013\left(a^2+b^2+c^2+d^2\right)=2013\left(2013^2\right)$

$a^3+b^3+c^3+d^3 \le 2013^3$

សមភាពកើតមានកាលណា មួយក្នុងចំណោម a,b,c និង d ស្មើនឹង 2013 ហើយចំនួនបីផ្សេងទៀតស្មើនឹង សូន្យ ។

ដូចនេះវិសមភាព $a^3+b^3+c^3+d^3 \le 2013^3$ ត្រូវបានស្រាយបញ្ជាក់ ។

249. រកគ្រប់អនុគមន៍ $f:\mathbb{R}\to\mathbb{R}$ ដែលផ្ទៀងផ្ទាត់លក្ខខណ្ឌ $f\left(xf\left(y\right)+x\right)=xy+f\left(x\right)$ ចំពោះគ្រប់ចំនួនពិត x និង y ។

<u>ដំណោះស្រាយ</u>

រកគ្រប់អនុគមន៍ f

យើងមាន , $f:\mathbb{R}\to\mathbb{R}$ ហើយផ្ទៀងផ្ទាត់លក្ខខណ្ឌ $f\left(xf\left(y\right)+x\right)=xy+f\left(x\right)$

ចំពោះគ្រប់ចំនួនពិត x និង y ។

យក $x=1, y=-1-f\left(1\right)$ និងតាង $a=f\left(y\right)+1$ យើងបាន ៖

$$f\left(a\right)=f\left(f\left(y\right)+1\right)=y+f\left(1\right)=-1$$

យក $y=a$ និងតាង $b=f\left(0\right)$ យើងបាន ៖

$$b=f\left(xf\left(a\right)+x\right)=ax+f\left(x\right)$$

នាំឲ្យគេបាន $f\left(x\right)=-ax+b$

ជំនួសអនុគមន៍ $f\left(x\right)=-ax+b$ ទៅក្នុងសមីការខាងលើ , គេបាន ៖

$$a^2xy-abx-ax+b=xy-ax+b$$

$$a^2xy-\left(ab+a\right)x+b=xy-ax+b$$

$$\begin{cases} a^2=1 \\ -\left(ab+a\right)=-a \\ b=b \end{cases}$$

$$\begin{cases} a=\pm 1 \\ ab=0 \end{cases} \Rightarrow \begin{cases} a=\pm 1 \\ b=0 \end{cases}$$

ដូចនេះអនុគមន៍ដែលត្រូវរកនោះគឺ $f\left(x\right)=x$ ឬ $f\left(x\right)=-x$ ។

250. នៅក្នុងរូប, $AQPB$ និង $ASRC$ គឺជាការ៉េ ហើយ AQS គឺជាត្រីកោណសម័ង្ស ។
បើ $QS=4$ និង $BC=x$ ។ ចូររកតម្លៃនៃ x ។



<u>ដំណោះស្រាយ</u>

រកតម្លៃនៃ x

<u>របៀបទី ១</u>

ក្នុងត្រីកោណសម័ង្ស AQS គេបាន ៖ $AQ=QS=SA$

ដោយ $QS=4$ គេបាន $AQ=AS=4$

ដោយ $AQPB$ និង $ASRC$ ជាការ៉េ នោះយើងបាន $AB=AQ=4$ និង $AC=AS=4$

ម្យ៉ាងទៀត , ក្នុងត្រីកោណសម័ង្ស AQS គេបាន ៖ $\angle QAS=60^o$

យើងបាន , $\angle BAC=360^o-90^o-90^o-\angle QAS=120^o$



សង់កម្ពស់ពីកំពូល A ចំពោះបាត BC និងតាងចំណុចជើងកម្ពស់នោះដោយ M
នោះតាមលក្ខណៈស៊ីមេទ្រី នាំឲ្យគេបាន M ជាចំណុចកណ្តាលនៃ BC និង

$$\angle BAM=\angle CAM=\frac{\angle BAC}{2}=\frac{120^o}{2}=60^o$$

គេបាន ABM ជាត្រីកោណកន្លះសម័ង្ស ។ គេបាន , $\frac{BM}{BA}=\frac{\sqrt{3}}{2}$

នាំឲ្យយើងបាន $BM=\frac{4\sqrt{3}}{2}=2\sqrt{3}$ ហើយ $CM=2\sqrt{3}$

ដូច្នេះ $x=BC=BM+MC=4\sqrt{3}$ ត្រូវបានគណនា ។

<u>របៀបទី</u> ២

តាមរបៀបទី១ ខាងលើ , គេមាន $AB = AC = 4$ និង $\angle BAC = 120^o$

តាមទ្រឹស្តីបទកូស៊ីនុស , យើងបាន ៖

$$BC^2 = AB^2 + AC^2 - 2\cdot AB\cdot AC\cdot\cos\angle BAC$$
$$BC^2 = 4^2 + 4^2 - 2\cdot 4\cdot 4\cdot\cos 120^o$$
$$BC^2 = 32 - 32\left(-\frac{1}{2}\right)$$
$$BC^2 = 32 + 16 = 48$$
$$BC = \sqrt{48} = 4\sqrt{3}$$

ដូចនេះ $x = BC = 4\sqrt{3}$ ត្រូវបានគណនា ។

<u>របៀបទី</u> ៣



តាង M, N ជាចំណុចកណ្តាលរៀងគ្នានៃ BC និង QS រៀងគ្នា ។ តាមលក្ខណៈស៊ីមេទ្រី M, A, N ឋិតនៅលើបន្ទាត់តែមួយ ហើយបន្ទាត់ MN កែងជាមួយនឹងបន្ទាត់ QS និង BC

តាមរបៀបទី១ , $\angle QAS = 60^o$ និង $\angle BAC = 120^o$ នោះតាមលក្ខណៈស៊ីមេទ្រី , គេបាន ៖ $\angle QAN = 30^o$ និង $\angle BAM = 60^o$ ។

ត្រីកោណ AQS ជាត្រីកោណសម័ង្ស , $\angle AQN = 60^o$

និង $\angle ABM = 180^o - \angle BAM - \angle AMB = 180^o - 60^o - 90^o = 30^o$

ហើយ $AB = AG$, ត្រីកោណ ANQ និង BMA ជាត្រីកោណប៉ុនគ្នា ។

យើងបាន , $BM = AN$

តាមទ្រឹស្តីបទពីតាគ័រ , គេបាន ៖

$$BM = AN = \sqrt{AQ^2 - QN^2}$$
$$x = BM = \sqrt{4^2 - 2^2} = 2\sqrt{3}$$

ដូចនេះ $x = BC = 4\sqrt{3}$ ត្រូវបានគណនា ។

251. $ABCD-EFGH$ គឺជាគូបមួយដែលមាន $ABCD$ ជាមុខលើ , តាមកំពូល H,G,F និង E គូសបន្ទាត់ដោយផ្ទាល់ភ្ជាប់ទៅកំពូល A,B,C និង D រៀងគ្នា ។ ចំនួនពិតមួយត្រូវបានដាក់នៅតាមកំពូលនីមួយៗ ។ ត្រង់កំពូលនីមួយៗ , មធ្យមនៃចំនួនក្នុងកំពូលជាប់គ្នាបី ។ មធ្យមដែលបិតនៅត្រង់ A,B,C,D,E,F,G,H គឺ $1,2,3,4,5,6,7,8$ រៀងគ្នា ។ រកចំនួនដែលបិតនៅត្រង់កំពូល F ។

<u>ដំណោះស្រាយ</u>

រកចំនួនដែលបិតនៅត្រង់កំពូល F



តាង a,b,c,d,e,f,g,h គឺជាចំនួនដែលត្រូវដាក់នៅត្រង់កំពូល A,B,C,D,E,F,G,H ។ ដំបូងយើងសំគាល់ឃើញថា ៖

$$a+b+c+d+e+f+g+h=1+2+3+4+5+6+7+8=36$$

គេទាញបាន , $c+f=36-(b+d+h)-(a+e+g)=36-3(A+H)$

ស្រដៀងគ្នាដែរ , យើងបាន ៖

$$e+f=36-3(A+B) \text{ និង } f+g=36-3(A+D)$$

គេបាន ៖

$$\begin{aligned}3f&=(c+f)+(e+f)+(f+g)-(c+e+g)\\&=\big(36-3(1+8)\big)+\big(36-3(1+2)\big)+\big(36-3(1+4)\big)-6\cdot 3\\&=39\end{aligned}$$

ដូចនេះគេបាន $f=13$ ជាចំនួនដែលគេត្រូវដាក់ត្រង់កំពូល F ។

252. គេឲ្យស្វ៊ីត ហ្វីបូណាស៊ី (u_n) កំណត់ដោយ ៖ $u_0=0,u_1=1$ និង $u_{n+1}=u_n+u_{n-1}$ គ្រប់ $n\geq 1$ ។

ក. រក u_n ជាអនុគមន៍នៃ n ។

ខ. បង្ហាញថា $u_1+u_2+\cdots+u_n=u_{n+2}-1$ គ្រប់ $n\in\mathbb{N}$ ។

ដំណោះស្រាយ

ក. រក u_n ជាអនុគមន៍នៃ n

យើងមាន $u_0 = 0, u_1 = 1$ និង គ្រប់ $n \geq 1$, $u_{n+1} = u_n + u_{n-1}$ (១)

ទំនាក់ទំនង(១)មានសមីការសម្គាល់ ៖ $r^2 = r + 1$

ដោះស្រាយសមីការសម្គាល់ គេបានចម្លើយ $r_{1,2} = \frac{1 \pm \sqrt{5}}{2}$

គេបាម(១) ៖

$$u_{n+1} = (r_1 + r_2)u_n - r_1 r_2 u_{n-1}$$

$$u_{n+1} - r_1 u_n = r_2 u_n - r_1 r_2 u_{n-1} \quad (២)$$

យក $v_n = u_n - r_1 u_{n-1}$ គ្រប់ $n \geq 1$

នោះ(២) ៖ $v_{n+1} = r_2 v_n$

ទំនាក់ទំនងនេះ បង្ហាញថា (v_n) ជាស្វ៊ីតធរណីមាត្រដែលមានផលសងរួម r_2 និងតួទី១ v_1

គេបាន ៖ $v_n = v_1 r_2^{n-1} \Rightarrow u_n - r_1 u_{n-1} = (u_1 - r_1 u_0) r_2^{n-1}$ (៣)

ម្យ៉ាងទៀត (១) ៖

$$u_{n+1} = (r_1 + r_2)u_n - r_1 r_2 u_{n-1}$$

$$u_{n+1} - r_2 u_n = r_1 u_n - r_1 r_2 u_{n-1} \quad (៤)$$

យក $w_n = u_n - r_2 u_{n-1}$ គ្រប់ $n \geq 1$

នោះ(៤) ៖ $w_{n+1} = r_1 w_n$

ទំនាក់ទំនងនេះ បង្ហាញថា (w_n) ជាស្វ៊ីតធរណីមាត្រដែលមានផលសងរួម r_1 និងតួទី១ w_1

គេបាន ៖ $w_n = w_1 r_1^{n-1} \Rightarrow u_n - r_2 u_{n-1} = (u_1 - r_2 u_0) r_1^{n-1}$ (៥)

តាម (៣) និង (៥) គេបាន ៖

$$\frac{(u_1 - r_1 u_0) r_2^{n-1}}{r_1} - \frac{u_n}{r_1} = \frac{(u_1 - r_2 u_0) r_1^{n-1}}{r_2} - \frac{u_n}{r_2}$$

ដោយ $u_0 = 0$, $u_1 = 1$ គេបាន ៖

$$\frac{r_2^{n-1}}{r_1} - \frac{u_n}{r_1} = \frac{r_1^{n-1}}{r_2} - \frac{u_n}{r_2}$$

$$u_n\left(\frac{1}{r_2} - \frac{1}{r_1}\right) = \frac{r_1^{n-1}}{r_2} - \frac{r_2^{n-1}}{r_1}$$

$$u_n(r_1 - r_2) = r_1^n - r_2^n$$

$$u_n = \frac{r_1^n - r_2^n}{r_1 - r_2}$$

$$u_n = \frac{1}{\frac{1+\sqrt{5}}{2} - \frac{1-\sqrt{5}}{2}}\left(\left(\frac{1+\sqrt{5}}{2}\right)^n - \left(\frac{1-\sqrt{5}}{2}\right)^n\right)$$

$$u_n = \frac{1}{\sqrt{5}}\left(\left(\frac{1+\sqrt{5}}{2}\right)^n - \left(\frac{1-\sqrt{5}}{2}\right)^n\right)$$

ដូចនេះគ្រប់ $n\ge 0, u_n=\frac{1}{\sqrt{5}}\left(\left(\frac{1+\sqrt{5}}{2}\right)^n-\left(\frac{1-\sqrt{5}}{2}\right)^n\right)$ ត្រូវបានកំណត់ ។

ខ. បង្ហាញថា $u_1+u_2+\cdots+u_n=u_{n+2}-1$ គ្រប់ $n\in\mathbb{N}$

យើងមាន $u_{n+1}=u_n+u_{n-1}$ គ្រប់ $n\ge 1$, គេបាន ៖

$$\begin{aligned}u_1&=u_2\\u_1+u_2&=u_3\\u_2+u_3&=u_4\\&\ldots\ldots\ldots\ldots\\u_n+u_{n+1}&=u_{n+2}\end{aligned}$$

បូកអង្គនឹងអង្គនៃសមីការ ទាំងអស់ខាងលើ , គេបាន ៖

$$u_1+(u_1+u_2+\cdots+u_n)=u_{n+2}$$

នាំឲ្យយើងបាន ៖ $u_1+u_2+\cdots+u_n=u_{n+2}-u_1=u_{n+2}-1$

ដូចនេះ $u_1+u_2+\cdots+u_n=u_{n+2}-1$ គ្រប់ $n\in\mathbb{N}$ ត្រូវបានបង្ហាញ ។

253. ក. បង្ហាញថា $A=11^{10}-1$ ចែកដាច់នឹង 600 ។

ខ. រកគ្រប់ចំនួនគត់ធម្មជាតិ n ដែលផ្ទៀងផ្ទាត់ $B=2^n+1$ ចែកដាច់នឹង 3 ។

<u>ដំណោះស្រាយ</u>

ក. បង្ហាញថា $A=11^{10}-1$ ចែកដាច់នឹង 600

យើងមាន $600=10\cdot 60=10\cdot 12\cdot 5$ គេបាន ៖

$$\begin{aligned}A&=11^{10}-1\\&=(11-1)\left(11^9+11^8+\cdots+11+1\right)\\&=10\left(11^9+11^8+\cdots+11+1\right)\vdots 10\end{aligned}$$

ហើយលើសពីនេះទៅទៀត ,

$$\begin{aligned}11^9+11^8+\cdots+11+1&=11^8(11+1)+11^6(11+1)+11^4(11+1)+11^2(11+1)+(11+1)\\&=12\left(11^8+11^6+11^4+11^2+1\right)\vdots 12\end{aligned}$$

ហើយ 11^k មានលេខខាងចុងជាលេខ 1 ចំពោះគ្រប់ចំនួនគត់មិនអវិជ្ជមាន k

នាំឲ្យ $11^8+11^6+11^4+11^2+1$ មានលេខខាងចុងជាលេខ 5

នាំឲ្យ $11^8+11^6+11^4+11^2+1\vdots 5$

នាំឲ្យ $A\vdots 10\cdot 12\cdot 5=600$

ដូចនេះ $A=11^{10}-1$ ចែកដាច់នឹង 600 ត្រូវបានស្រាយបញ្ជាក់ ។

ខ. រកគ្រប់ចំនួនគត់ធម្មជាតិ n ដែលផ្ទៀងផ្ទាត់ $B=2^n+1$ ចែកដាច់នឹង 3

យើងមាន ៖ $2\equiv -1(\text{mod}\,3)\Rightarrow 2^n\equiv(-1)^n(\text{mod}\,3)$, $n\in\mathbb{N}$

នាំឲ្យ $2^n+1\equiv\left((-1)^n+1\right)(\text{mod}\,3)$

ដោយ $B=2^n+1$ ចែកដាច់នឹង 3 នោះ $(-1)^n+1$ ចែកដាច់នឹង 3

នាំឱ្យ $n=2k+1$, $k\in\mathbb{N}$

ដូចនេះបំនួនគត់ធម្មជាតិនោះគឺ $n=2k+1,\ k\in\mathbb{N}$ (n ជាបំនួនគត់ធម្មជាតិ) ។

254. ដោះស្រាយសមីការ $8x^3+24x^2+6x-1=0$ ។

<u>ដំណោះស្រាយ</u>

ដោះស្រាយសមីការ $8x^3+24x^2+6x-1=0$

សមីការអាចសរសេរជា $x^3+3x^2+\frac{3}{4}x-\frac{1}{8}=0$ (១)

តាង $y=x+1$ នោះ $x=y-1$

គេបាន (១) ៖

$$(y-1)^3+3(y-1)^2+\frac{3}{4}(y-1)-\frac{1}{8}=0$$

$$y^3-\frac{9}{4}y+\frac{9}{8}=0 \qquad (២)$$

តាង $z=\dfrac{y}{2\sqrt{-\frac{p}{3}}}$ ដែល $p=-\frac{9}{4}$ នោះ $z=\frac{y}{\sqrt{3}}$ នាំឱ្យ $y=\sqrt{3}z$

គេបាន (២) ៖

$$\left(\sqrt{3}z\right)^3-\frac{9}{4}\left(\sqrt{3}z\right)+\frac{9}{8}=0$$

$$4z^3-3z=-\frac{\sqrt{3}}{2} \qquad (៣)$$

ដោយ $-1<-\frac{\sqrt{3}}{2}<1$ គេតាង $z=\cos\alpha$, $0<\alpha<2\pi$

នោះគេបាន (៣) ៖

$$4\cos^3\alpha-3\cos\alpha=\cos\frac{5\pi}{6}$$

$$\cos 3\alpha=\cos\frac{5\pi}{6}$$

$$\alpha=\frac{5\pi}{18}+\frac{2k\pi}{3}\ ,\ k=0,1,2$$

នាំឱ្យ $\alpha_1=\frac{5\pi}{18},\alpha_2=\frac{17\pi}{18},\alpha_3=\frac{29\pi}{18}$

នោះ $z_1=\cos\frac{5\pi}{18},z_2=\cos\frac{17\pi}{18},z_3=\cos\frac{29\pi}{18}$

នាំឱ្យ $y_1=\sqrt{3}\cos\frac{5\pi}{18},y_2=\sqrt{3}\cos\frac{17\pi}{18},y_3=\sqrt{3}\cos\frac{29\pi}{18}$

សមមូល $x_1=\sqrt{3}\cos\frac{5\pi}{18}-1,x_2=\sqrt{3}\cos\frac{17\pi}{18}-1,x_3=\sqrt{3}\cos\frac{29\pi}{18}-1$

ដូចនេះសមីការមានឫស $x_1=\sqrt{3}\cos\frac{5\pi}{18}-1, x_2=\sqrt{3}\cos\frac{17\pi}{18}-1$ និង $x_3=\sqrt{3}\cos\frac{29\pi}{18}-1$ ។

255. ក. គេឲ្យសមីការ $x^4+bx^3+cx^2+bx+1=0$ មានឫស ។ បង្ហាញថា $b^2+(c-2)^2>3$ ។

ខ. ដោះស្រាយសមីការ $x^3+3x-3=0$ ។

<u>ដំណោះស្រាយ</u>

ក. បង្ហាញថា $b^2+(c-2)^2>3$

យើងមាន , សមីការ $x^4+bx^3+cx^2+bx+1=0$

សមីការខាងលើអាចសរសេរ ៖

$$x^2+bx+c+\frac{b}{x}+\frac{1}{x^2}=0$$

$$\left(x^2+\frac{1}{x^2}\right)+b\left(x+\frac{1}{x}\right)+c=0 \qquad (១)$$

តាង $t=x+\frac{1}{x}$ នោះ $x^2+\frac{1}{x^2}=t^2-2 \ , |t|\geq 2$

នាំឲ្យ(១) ៖

$$t^2+bt+c-2=0$$

$$t^2=(2-c)-bt$$

តាមវិសមភាព BUNHIACOPSKI គេបាន ,

$$t^4=((2-c)-bt)^2\leq\left((2-c)^2+b^2\right)\left(t^2+1\right)$$

$$\frac{t^4}{t^2+1}\leq(2-c)^2+b^2 \qquad (២)$$

ដោយ $|t|\geq 2$ នោះ $t^4\geq 16$ ហើយ ,

$$t^4-3\left(t^2+1\right)=t^4-3t^2-3\geq 16-3\cdot 4-3>0$$

$$t^4>3\left(t^2+1\right)$$

នោះ $\frac{t^4}{t^2+1}>3 \qquad (៣)$

តាម(២) និង(៣) នាំឲ្យគេបាន ៖ $b^2+(2-c)^2>3$ ។

ដូចនេះវិសមភាព $b^2+(c-2)^2>3$ ត្រូវបានស្រាយបញ្ជាក់ ។

ខ. ដោះស្រាយសមីការ

យើងមានសមីការ $x^3+3x-3=0 \qquad (១)$

តាង $x=y-\frac{1}{y}$ គេបាន (១) ៖

